ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ
# នៅកម្ពុជាឆ្នាំ ២០២៣-២០៣៥



# ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ
# នៅកម្ពុជាឆ្នាំ ២០២៣-២០៣៥

“ដើម្បីផលិត ឬប្រែក្លាយកម្លាំងពលកម្ម ឬធនធានមនុស្សកម្ពុជា ជាធនធានជន្ទល់ សម្រាប់អភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិដែលប្រកបដោយសមត្ថភាព និងផលិតភាពខ្ពស់ ឆ្លើយតបនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ននិងអនាគត និងផ្តល់ឱកាសទទួលបាន ការសិក្សាពេញមួយជីវិត និងធានាថាប្រជាពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិច ប្រចាំជីវិត មានការងារធ្វើល្អសមរម្យ មានសេចក្តីថ្លៃថ្នូរ និងមានកម្រិតជីវភាព កាន់តែប្រសើរឡើង”

រៀបចំដោយ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ឆ្នាំ២០២៣**

# បុព្វកថា

ក្រោមកត្តាសុខសន្តិភាព បូរណភាពទឹកដី សាមគ្គីភាព និងស្ថិរភាពនយោបាយ រាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំប្រទេសនិងអនុវត្តគោលនយោបាយជាតិគន្លឹះៗ រួមមានជាអាទិ៍ **គោលនយោបាយ «ឈ្នះ-ឈ្នះ» យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិតាមវិស័យ និងកម្មវិធីកែទម្រង់ផ្សេងៗ** ដោយសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈជូនជាតិមាតុភូមិ និងប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ ក្នុងរយៈពេលជិត៣ទសវត្សរ៍កន្លងមកនេះ។ មូលដ្ឋានគ្រឹះទាំងនេះជាបុរេលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន ដែលអនុញ្ញាតឱ្យកម្ពុជាប្រែមុខមាត់លើឆាកអន្តរជាតិ និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ៧,៧% ដែលបានរួមចំណែកកាត់បន្ថយអត្រាភាពក្រីក្រ បង្កើតការងារជូនប្រជាពលរដ្ឋពេញផ្ទៃប្រទេស និងជំរុញការអភិវឌ្ឍប្រកបដោយបរិយាបន្ន។ ជាក់-ស្តែង សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងសមិទ្ធផលជាតិទាំងនេះបានដើរតួជាកាតាលីករ ក្នុងការផ្តល់លទ្ធភាពឱ្យកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប និងត្រូវបានធនាគារពិភពលោកទទួលស្គាល់និងចាត់ចូលក្នុងចំណោមប្រទេស «**ឯតទគ្គករកំណើន**» ទាំងប្រាំបីនៅលើពិភពលោកក្នុងឆ្នាំ២០១៥ ផងដែរ។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់នូវគោលដៅធ្វើពិពិធកម្ម និងទំនើបកម្មសេដ្ឋកិច្ចកម្ពុជា ដោយប្រែក្លាយសេដ្ឋកិច្ចអតិពលកម្មទៅជាសេដ្ឋកិច្ចដែលផ្អែកលើជំនាញ និងមានតម្លៃបន្ថែមកាន់តែខ្ពស់ ដើម្បីរក្សាចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដើម្បីកសាងមូលដ្ឋានគ្រឹះចាំបាច់ឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និង ២០៥០។ ដើម្បីសម្រេចគោលដៅធ្វើពិពិធកម្ម និងទំនើបកម្មសេដកិច្ចកម្ពុជាខាងលើ រាជរដ្ឋាភិបាលកម្ពុជាយល់ច្បាស់ពីសារៈសំខាន់នៃការអភិវឌ្ឍជំនាញប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ និងផលិតភាពខ្ពស់ ដែលជាកត្តាស្នូលមួយដ៏សំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការជំនាញនាពេលបច្ចុប្បន្ន និងអនាគតរបស់សេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអភិវឌ្ឍជំនាញ តាមរយៈការជំរុញការអនុវត្ត **គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥** ដែលរួមចំណែកដោះស្រាយបញ្ហាប្រឈមសំខាន់ៗ ដោយ ១.) ពង្រឹងគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យស្របតាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស ២.) បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយសមធម៌សម្រាប់បង្កើតការងារ ៣.) លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឱ្យចូលរួមក្នុងការអភិវឌ្ឍ និងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និង ៤.) លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ បន្ថែមពីនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយមួយចំនួនទៀតដើម្បីជាមគ្គុទេសក៍ក្នុងការតម្រង់ទិស និងគាំទ្រគ្នាទៅវិញទៅមកក្នុង

ការអនុវត្ត សំដៅចាប់យកនូវកាលានុវត្តភាពនៃការវិវត្តសង្គមសេដ្ឋកិច្ច និងនិន្នាការក្នុងតំបន់និងសកលលោក ក្នុងនោះរួមមានគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ២០៣០ ដើម្បីជំរុញប្រជាពលរដ្ឋក្នុងការមានការងារធ្វើល្អ និងកម្រិតជីវភាពកាន់តែប្រសើរឡើង លើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ បង្កើនបាននូវកម្លាំងពលកម្ម ឬមូលធនមនុស្សកម្ពុជា ប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញឥរិយាបថការងារ ផលិតភាពខ្ពស់ និងកាន់តែមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត និងធានាថា *"ប្រជាពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"*។

ទោះបីយ៉ាងនេះក្តី វិបត្តិជំងឺកូវីដ-១៩ បាននាំមកនូវបរិបទថ្មីនៃការរស់នៅ ការអនុវត្តការងារ ការធ្វើអាជីវកម្ម និងពាណិជ្ជកម្ម ដែលទាមទារឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការប្រចាំថ្ងៃកាន់តែទូលំទូលាយជាងមុន និងឈានទៅបោះបង់ចោលនូវការប្រើប្រាស់ជំនាញមួយចំនួន។ កម្ពុជាក៏កំពុងទទួលរងផលប៉ះពាល់អវិជ្ជមានពីនិន្នាការថ្មីនេះ ដោយសារភាគច្រើននៃកម្លាំងពលកម្មនៅកម្ពុជាមានជំនាញទាប និងមិនទាន់សមស្របនឹងតម្រូវការទីផ្សារ ខណៈដែលចំណេះដឹងឌីជីថលក៏នៅមានកម្រិត។ ថ្វីត្បិតរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជំរុញការអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធដែលជាការផ្តួចផ្តើមនានា ការអភិវឌ្ឍជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ នៅជួបប្រទះបញ្ហាប្រឈមដែលមានលក្ខណៈជាប្រព័ន្ធ រួមមាន១.) កង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមបណ្តាគ្រឹះស្ថានបណ្តុះបណ្តាល ២.) កង្វះភាពជាអ្នកដឹកនាំ និងយន្តការសម្របសម្រួលអន្តរស្ថាប័ន ៣.) មូលដ្ឋាន និងតំណភ្ជាប់ឧស្សាហកម្មនៅមានភាពតូចចង្អៀតនិងទន់ខ្សោយ ៤.) កង្វះគ្រូបណ្តុះបណ្តាល និងអ្នកជំនាញពីតម្រូវការឧស្សាហកម្មក្នុងការអភិវឌ្ឍកម្មវិធីសិក្សា ៥.) ការចូលរួមអនុវត្ត ឬកម្មសិក្សាផ្ទាល់របស់សិក្ខាកាមក្នុងឧស្សាហកម្មនៅមានកម្រិត ជាដើម។

ក្នុងន័យនេះ ដើម្បីរួមចំណែកដោះស្រាយបញ្ហាប្រឈមដែលមានលក្ខណៈជាប្រព័ន្ធក្នុងការអភិវឌ្ឍជំនាញ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញឱ្យអនុវត្តនូវ**ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ២០២៣-២០៣៥** នេះឡើង ដើម្បីតម្រង់ទិសនិងបន្សីនូវកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍជំនាញប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ និងផលិតភាពខ្ពស់ ដែលអាចឆ្លើយតបទៅនឹងតម្រូវការវិស័យឯកជននាពេញបច្ចុប្បន្ន និងអនាគត។ បន្ថែមពីនេះ ផែនទីបង្ហាញផ្លូវនេះមានលក្ខណៈប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមកជាមួយ**ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ ឆ្នាំ២០២៣-២០២៧** ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រែក្លាយឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាឱ្យកាន់តែមានភាពប្រកួតប្រជែងខ្ពស់ និងបង្កើនតម្លៃបន្ថែមក្នុងខ្សែច្រវាក់តម្លៃ ចីរភាពបរិស្ថាន ការប្រើប្រាស់បច្ចេកវិទ្យាជំនាញ និងសហគ្រិនភាព ព្រមទាំងចូលរួមគាំទ្រ ដល់ការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រតាមវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាផ្សេងទៀត តាមរយៈការដាក់ចេញនូវវិធានការមុតស្រួចនិងជាក់លាក់សម្រាប់អនុវត្ត។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និងការកោតសរសើរ ជូនចំពោះអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានសហការដឹកនាំ សម្របសម្រួល និងរៀបចំ**ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ២០២៣-២០៣៥** នេះឡើង ដោយបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធសំខាន់ៗ ក្នុងវិស័យសាធារណៈ និងជាពិសេសវិស័យឯកជន។ បន្ថែមពីនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា (ADB) ដែលបានសហការយ៉ាងជិតស្និទ្ធ និងផ្តល់ការគាំទ្រនានាទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំនិងដាក់ឱ្យអនុវត្តនូវផែនទីបង្ហាញផ្លូវស្តីពី ការអភិវឌ្ឍជំនាញនៅកម្ពុជាដ៏មានសារៈសំខាន់នេះឡើង។

ជាទីបញ្ចប់ ខ្ញុំជឿជាក់ថា គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនឹងចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញប្រកបដោយការប្តេជ្ញាចិត្ត បុរេសកម្ម អន្តរសកម្ម និងស្មារតីទទួលខុសត្រូវក្នុងការអនុវត្តផែនទីបង្ហាញផ្លូវនេះ និងដោយប្រកាន់ភ្ជាប់នូវអភិក្រម និងអនុសាសន៍ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញកន្លងមក «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**» និង «**កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីពង្រឹងឯករាជ្យនិងអធិបតេយ្យភាពជាតិ**» សំដៅចូលរួមចំណែកក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែង និងផលិតភាពកាន់តែខ្ពស់ ដែលជំរុញដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជា ការឆ្លើយតបទៅនឹងការរំពឹងទុកនិងតម្រូវការរបស់ប្រជាជន និងការកសាងមូលដ្ឋានគ្រឹះចាំបាច់ ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និង ២០៥០។

ថ្ងៃសុក្រ ១១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

និម្មាបនកម្មសេដ្ឋកិច្ចជាតិ និងសកលលោក បានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស រួមទាំងភាពជឿនលឿននៃផ្នែកបច្ចេកវិទ្យាក្នុងបដិវត្តន៍ឧស្សាហកម្ម ៤.០ គម្លាតជំនាញ និងការប្រែប្រួលក្នុងពិភពការងារ និងផលប៉ះពាល់នៃជំងឺកូវីដ បានបង្ហាញនូវការប្រឈម និងឱកាសថ្មីៗជាច្រើនដល់វិស័យនានានៅក្នុងប្រទេសកម្ពុជា ដែលទាមទារឱ្យមានការរៀបចំឱ្យបានច្បាស់លាស់ក្នុងការផលិតនូវកម្លាំងពលកម្មដែលប្រកបដោយសមត្ថភាព ជំនាញ និងភាពប្រកួតប្រជែងឆ្លើយតបនឹងតម្រូវការឧស្សាហកម្មនាពេលបច្ចុប្បន្ន និងអនាគត។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ និងដើម្បីចូលរួមសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង២០៥០ រាជរដ្ឋាភិបាលបានចាត់ទុកការអភិវឌ្ឍមូលធនមនុស្សដែលជាធនធានជន្ទល់គាំទ្រការរីកចម្រើនសង្គមសេដ្ឋកិច្ចជាតិជាអាទិភាពចម្បង ដែលតម្រូវឱ្យកម្ពុជាត្រូវមានផែនទីមួយជាក់លាក់ជាមាគ៌ាចង្អុលបង្ហាញផ្លូវក្នុងការអភិវឌ្ឍធនធានមនុស្ស។

ហេតុដូចនេះទើបផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ២០២៣-២០៣៥ ត្រូវបានបង្កើតឡើង ដើម្បីធ្វើជាឯកសារយុទ្ធសាស្ត្រណែនាំដល់គ្រប់តួអង្គពាក់ព័ន្ធនីមួយៗក្នុងការរៀបចំផែនការជាក់លាក់របស់ខ្លួនដើម្បីចូលរួមពង្រឹងគុណភាពនៃការអភិវឌ្ឍជំនាញកម្ពុជាឱ្យមានលទ្ធភាពបំពេញសក្តានុពលនៃការរីកចម្រើននាពេលបច្ចុប្បន្ន និងអនាគត សំដៅចូលរួមរក្សា និងជំរុញកំណើនសេដ្ឋកិច្ចជាតិក្នុងរយៈពេលខ្លី មធ្យម និងវែងក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព។

ជារួមផែនទីបង្ហាញផ្លូវនេះមានសសរស្តម្ភគោលបំណងចំនួន៥៖ ១.) ការពង្រឹងគុណភាពការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, ២.) ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ, ៣.) ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម, ៤.) អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ, ៥.) ការផ្តល់ហិរញ្ញប្បទាន និងចីរភាព, ព្រមទាំងមានសកម្មភាពអន្តរាគមន៍ មានសូចនាករសមិទ្ធកម្មដែលមានភាពប្រទាក់ក្រឡាគ្នា និងគាំទ្រដល់គោលដៅតាមសសរស្តម្ភយុទ្ធសាស្ត្រនីមួយៗ។

ផែនទីបង្ហាញផ្លូវត្រូវបានរៀបចំឡើងដោយធ្វើការបន្សុីគ្នានឹងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និង២០៥០ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច

និងសង្គមខ្ចីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ២០៣០ និង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០។

ជាទីបញ្ចប់ក្នុងនាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងយ៉ាងមោះមុតរបស់ក្រុមការងារបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដៃគូអភិវឌ្ឍន៍ ក្រសួង-ស្ថានប័នពាក់ព័ន្ធ ជំនាញការ ដែលបានចូលរួមយ៉ាងសកម្មរៀបចំឯកសារនេះឡើង។ ជាមួយគ្នានេះ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដែលបានផ្តល់ការគាំទ្រ ដឹកនាំ សម្របសម្រួល ពិនិត្យ និងផ្តល់សុពលភាពលើផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជាឆ្នាំ២០២៣-២០៣៥ ដ៏មានសារៈសំខាន់នេះតាំងពីដើមរហូតដល់បញ្ចប់ជាស្ថាពរ។

ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ក្រសួងស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់ នឹងចូលរួមអនុវត្ត **ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ២០២៣-២០៣៥** ប្រកបដោយប្រសិទ្ធភាព និងជោគជ័យនាពេលអនាគត។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**បណ្ឌិត អ៊ិត សំហេង**

# បញ្ជីពាក្យកាត់

| ល.រ | ពាក្យកាត់ ខ្មែរ/អង់គ្លេស | ពាក្យពេញជាភាសាខ្មែរ | ពាក្យពេញជាភាសាអង់គ្លេស |
|---|---|---|---|
| ១ | ក្រសួង ក.ន. | ក្រសួងកិច្ចការនារី | Ministry of Women's Affairs |
| ២ | ក្រសួង ក.ប. | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | Ministry of Labour and Vocational Training |
| ៣ | ក្រសួង ផ.ក. | ក្រសួងផែនការ | Ministry of Planning |
| ៤ | ក្រសួង ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | Ministry of Economy and Finance |
| ៥ | ក្រសួង ស.អ.យ. | ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | Ministry of Social Affairs Veterans and Youth Rehabilitation |
| ៦ | ក្រសួង អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា | Ministry of Education, Youth and Sport |
| ៧ | ក្រសួង ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | Ministry of Industry, Science, Technology and Innovation |
| ៨ | គ.ជ.ប.ប. | គណៈកម្មាធិការជាតិបណ្តុះបណ្តាល | National Training Board |
| ៩ | ទ.ជ.ម.ក. | ទីភ្នាក់ងារជាតិមុខរបរ និងការងារ | National Employment Policy |
| ១០ | អ.ប.វ. | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | Technical Vocational Education and Training |
| ១១ | ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| ១២ | AFD | ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ | Agence Française de Développement |
| ១៣ | BTMA | សមាគមវាយនភណ្ឌ បង់ក្លាដែស | Bangladesh Textile Mills Association |
| ១៤ | CAMFEBA | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា | Cambodian Federation Of Employers And Business Associations |
| ១៥ | CAT | បច្ចេកវិទ្យាកម្មវិធីកុំព្យូទ័រ | Computer Applications Technology |
| ១៦ | CBT | ការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព | Competency-Based Training |
| ១៧ | CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | Council for the Development of Cambodia |
| ១៨ | DGTVET | អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | Directorate General of Technical Vocational Education and Training |
| ១៩ | IDP | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម | Industrial Development Policy |
| ២០ | IEC | ព័ត៌មាន ការអប់រំ និងទំនាក់ទំនង | Information Education and Communication |
| ២១ | ILO | អង្គការអន្តរជាតិខាងការងារ | International Labor Organization |

| | | | |
|---|---|---|---|
| ២២ | IMC | គណៈកម្មាធិការគ្រប់គ្រងវិទ្យាស្ថាន | Institute Management Committee |
| ២៣ | ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | Institute of Technology of Cambodia |
| ២៤ | ITI | គ្រឹះស្ថានបច្ចេកទេសឧស្សាហកម្ម | Industrial Technical Institutions |
| ២៥ | LMIS | ប្រព័ន្ធព័ត៌មានទីផ្សារការងារ | Labor Market Information System |
| ២៦ | NITRE | វិទ្យាស្ថានជាតិវិស្វកម្មវាយនភណ្ឌ និងស្រាវជ្រាវ | National Institute of Textile Research and Engineering |
| ២៧ | RIS | កម្មវិធីត្រឡប់ទៅឧស្សាហកម្មវិញ | Return to Industry Scheme |
| ២៨ | RTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលភូមិភាគ | Regional Training Centers |
| ២៩ | S4C | ការប្រកួតប្រជែងជំនាញ | Skills for Competition |
| ៣០ | SDC | ភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ | Swiss Agency for Development and Cooperation |
| ៣១ | SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | Sustainable Development Goals |
| ៣២ | SDIB | វិទ្យាស្ថានអភិវឌ្ឍន៍ជំនាញ Bhubaneswar | Skills Development Institute of Bhubaneswar |
| ៣៣ | SEZ | តំបន់សេដ្ឋកិច្ចពិសេស | Special Economic Zones |
| ៣៤ | SOP | នីតិវិធីប្រតិបត្តិតាមស្តង់ដា | Standard Opearional Procedure |
| ៣៥ | T&A | វាយនភណ្ឌ និងសំលៀកបំពាក់ | Textile & Apparel |
| ៣៦ | TP | អ្នកផ្តល់ការបណ្តុះបណ្តាល | Training Providers |
| ៣៧ | TVET | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | Technical Vocational Education and Training |
| ៣៨ | TVETSDP | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | Technical and Vocational Education and Training Sector Development Program |
| ៣៩ | TVP | សួនអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | TVET Park |
| ៤០ | UNIDO | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មរបស់អង្គការសហប្រជាជាតិ | The United Nations Industrial Development Organization |

## ខ្លឹមសារសង្ខេប

ផែនទីបង្ហាញផ្លូវនេះជាឯកសារយុទ្ធសាស្ត្រ ណែនាំដល់គ្រប់តួអង្គពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញដើម្បីចូលរួមពង្រឹងគុណភាពនៃការអភិវឌ្ឍជំនាញនៅកម្ពុជា ឱ្យមានលទ្ធភាពបំពេញសក្តានុពលនៃការរីកចម្រើននាពេលបច្ចុប្បន្ន និងអនាគត និងដើម្បីចូលរួមរក្សា និងជំរុញកំណើនសេដ្ឋកិច្ចជាតិក្នុងរយៈពេលខ្លី មធ្យម និងវែង ក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព។ ផែនទីបង្ហាញផ្លូវនេះ ត្រូវបានរៀបចំឡើងស្របទៅតាមទស្សនៈវិស័យកម្ពុជា ឆ្នាំ២០៣០និង ២០៥០ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ និងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ២០៣០ ព្រមទាំងបានបន្សុីគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព (SDGs) ផងដែរ។

ផែនទីបង្ហាញផ្លូវនេះមានចក្ខុវិស័យដើម្បីផលិត ឬប្រែក្លាយកម្លាំងពលកម្ម ឬធនធានមនុស្សកម្ពុជាជាធនធានជន្ទល់សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិដែលប្រកបដោយសមត្ថភាព និងផលិតភាពខ្ពស់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ននិងអនាគត និងផ្តល់ឱកាសទទួលបានការសិក្សាពេញមួយជីវិត និងធានាថាប្រជាពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត មានការងារធ្វើសមរម្យនិងល្អ មានសេចក្តីថ្លៃថ្នូរ និងមានកម្រិតជីវភាពកាន់តែប្រសើរឡើង។

ផែនទីបង្ហាញផ្លូវនេះមានសសរស្តម្ភយុទ្ធសាស្ត្រចំនួន៥ គោលដៅសរុបចំនួន២៦ និងសមិទ្ធកម្មគន្លឹះចំនួន២៧ និងបានរៀបចំជាសកម្មភាពអន្តរាគមន៍ និងសូចនាករសមិទ្ធកម្មតាមអន្តរាគមន៍នីមួយៗចំនួន ៧៥ ដែលត្រូវបានរៀបចំឡើងប្រទាក់ក្រឡាគ្នាតាមគោលដៅ និងសសរស្តម្ភយុទ្ធសាស្ត្រនីមួយៗ។

**១. ការពង្រឹងគុណភាព អ.ប.វ.៖** ការពង្រឹងគុណភាព អ.ប.វ. ឆ្ពោះទៅរកការផលិតនូវបណ្តុំកម្លាំងពលកម្មជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់ឆ្លើយតបនឹងម្រូវការទីផ្សារការងារ និងបានត្រៀមខ្លួនរួចរាល់សម្រាប់ចូលឧស្សាហកម្មតាមរយៈការអនុវត្តពេញលេញនូវក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា, ការធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព, ការធ្វើឱ្យកម្មវិធីបណ្តុះបណ្តាលមានភាពទន់ភ្លន់, ការធ្វើបរិវត្តកម្មគ្រឹះស្ថានអ.ប.វ., ការធ្វើវិក្រឹត្យការ អធិការកិច្ច និងវាយតម្លៃសមត្ថភាពគ្រូបច្ចេកទេស, និងការបន្សុីគ្នានឹងក្របខ័ណ្ឌគុណវុឌ្ឍិយោងកម្រិតតំបន់ និងពង្រឹងក្រុមប្រឹក្សាអភិវឌ្ឍន៍ជំនាញដែលមានស្រាប់។

២. **ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ៖** ការកសាងកិត្តិនាមនិងអត្តសញ្ញាណ និងបង្កើនការផ្សព្វផ្សាយគ្រប់ទម្រង់ឱ្យបានដល់សហគមន៍ដើម្បីបង្កើនភាពទាក់ទាញ ពង្រឹងការតម្រង់ទិសវិជ្ជាជីវៈដើម្បីបង្កើនការយល់ដឹង ការផ្លាស់ប្តូរផ្នត់គំនិត ការផ្តល់តម្លៃនិងសារៈសំខាន់ ការជំរុញឱ្យមានក្តីស្រមៃ និងមោទកភាពក្នុងការចាប់យក អ.ប.វ.។ ការរៀបចំកម្មវិធី អ.ប.វ. ដោយបញ្ចូលនូវការលើកកម្ពស់សហគ្រិនភាពឱកាសហ្វឹកហ្វឺនកូនជាង និងប្រកបដោយបរិយាប័ន្នដែលមិនទុកនរណាម្នាក់ចោលដោយបង្កលទ្ធភាពងាយស្រួលដល់ក្រុមជនងាយរងគ្រោះចូលមកសិក្សានៅផ្នែក អ.ប.វ.។

៣. **អ.ប.វ. ដែលឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម៖** សំដៅដល់ការពង្រីកតួនាទី ភារកិច្ច និងការចូលរួមរបស់វិស័យឯកជននៅក្នុងការអភិវឌ្ឍជំនាញ ពង្រឹង និងពង្រីកបណ្តាញរវាងគ្រឹះស្ថានអ.ប.វ. និងឧស្សាហកម្ម, លើកកម្ពស់ការរៀបចំជំនាញឡើងវិញ (Reskilling) និងការបង្កើនជំនាញ (Upskilling) និងបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យបន្ថែមទៀត។

៤. **អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ៖** ពង្រឹងអភិបាលកិច្ចប្រព័ន្ធអ.ប.វ. ដោយបន្តអភិវឌ្ឍច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពង្រឹងយន្តការអន្តរស្ថាប័នដើម្បីជំរុញការត្រួតពិនិត្យនិងគ្រប់គ្រង។ ពង្រឹងប្រព័ន្ធធានាគុណភាព ពង្រឹងសមត្ថភាពគ្រប់គ្រងនិងដឹកនាំ និងការបង្កើតគណៈកម្មាធិការគ្រប់គ្រងនៅតាមគ្រឹះស្ថាន អ.ប.វ.។

៥. **ការផ្តល់ហិរញ្ញប្បទាន និងចីរភាព៖** ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន អ.ប.វ. និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន, ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ ដោយឆ្ពោះទៅរកការអនុវត្តផ្អែកលើលទ្ធផល និងស្វ័យភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញ, បង្កើនការវិភាជន៍ថវិកាថ្នាក់ជាតិសម្រាប់ អ.ប.វ./ការអភិវឌ្ឍជំនាញ។

ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ និងជាមូលដ្ឋានគន្លឹះសម្រាប់ការរៀបចំផែនការ និងការសម្រេចចិត្តដោយផ្អែកលើភ័ស្តុតាង យើងត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាពមួយដែលគ្រប់គ្រងដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដើម្បីពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់គ្រប់តួអង្គពាក់ព័ន្ធដោយត្រូវបញ្ជូនរបាយការណ៍មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលជាសេនាធិការដើម្បីធ្វើការរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពជាទៀងទាត់ ជាប្រចាំឆ្នាំ និងជារៀងរាល់កំឡុង៣ឆ្នាំម្តងសំដៅកែសម្រួលគោលដៅ អន្តរាគមន៍ និងសូចនាករសមិទ្ធកម្មទៅតាមតម្រូវការជាក់ស្តែង។ ទន្ទឹមនឹងនេះឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់ពិនិត្យ និងវាយតម្លៃ និងត្រូវបានបង្កើតឡើងសម្រាប់សូចនាករនីមួយៗ ដើម្បីធានាភាពច្បាស់លាស់ ហើយក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិស័យតាមបែបឌីជីថល "ប្រកជំនាញជាតិ" នឹងត្រូវបានបង្កើតឡើង

ដើម្បីសម្រួលការក្តោបយកនូវវឌ្ឍនភាពតាមសសរស្តម្ភយុទ្ធសាស្ត្រ គោលដៅ អន្តរាគមន៍ និងសូចនាករសមិទ្ធកម្មដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវនេះ។

# មាតិកា


បុព្វកថា ........ i

អារម្ភកថា........ iii

បញ្ជីពាក្យកាត់........ v

ខ្លឹមសារសង្ខេប ........ viii

ផ្នែកទី១៖ សេចក្តីផ្តើម ........ ១

ផ្នែកទី២៖ អភិក្រមប្រើប្រាស់ក្នុងការរៀបចំផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ........ ៣

ផ្នែកទី៣៖ ចក្ខុវិស័យ គោលបំណង គោលដៅនៃផែនទីបង្ហាញផ្លូវ ........ ៥

៣.១.ចក្ខុវិស័យ........ ៥

៣.២.គោលបំណង........ ៥

៣.៣.គោលដៅ និងសូចនាករសមិទ្ធកម្មគន្លឹះ........ ៧

ផ្នែកទី៤៖ តួនាទីរបស់តួអង្គពាក់ព័ន្ធសំខាន់ៗ ........ ១០

ផ្នែកទី៥៖ ការតាមដាននិងវាយតម្លៃ........ ១៥

ផ្នែកទី៦៖ តារាងម៉ាទ្រិកលម្អិតអន្តរាគមន៍ និងសូចនាករសមិទ្ធកម្ម តាមគោលដៅ និងសសរស្តម្ភ ..១៦

ផ្នែកទី៧៖ សេចក្តីសន្និដ្ឋាន ........ ៦៨

ឧបសម្ព័ន្ធ៖ តារាងគោលដៅគន្លឹះដែលពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញ ដកស្រង់ពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ ........ ៦៩

# ផ្នែកទី១៖ សេចក្តីផ្តើម

ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ចក្នុងតំបន់និងសកលលោក បដិវត្តកម្មនៃបច្ចេកវិទ្យាចុងក្រោយ បដិវត្តន៍ឧស្សាហកម្ម ៤.០ គម្លាតជំនាញនិងការប្រែប្រួលក្នុងពិភពការងារ និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនយ៉ាងមោះមុតក្នុងការចូលរួមដោះស្រាយការប្រឈមខាងលើតាមរយៈការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយអនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្រនានារួមមាន៖ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង២០៥០ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ និងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០។ បន្ថែមពីលើនេះ ដោយមើលឃើញសារៈសំខាន់នៃការអភិវឌ្ឍជំនាញកម្ពុជាមានតួអង្គដៃគូអភិវឌ្ឍន៍ជាច្រើនបានផ្តល់មូលនិធិលើគម្រោងដើម្បីធ្វើបរិវត្តកម្ម ទំនើបកម្ម និងពង្រឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាបន្តបន្ទាប់។ ការណ៍នេះបានបង្ហាញយ៉ាងច្បាស់ថារាជរដ្ឋាភិបាលវិស័យសង្គមទាំងអង្គការជាតិ និងអន្តរជាតិពិតជាមានការយល់ឃើញស្របគ្នាថា ការអភិវឌ្ឍជំនាញពិតជាគន្លឹះអាទិភាពសម្រាប់ចូលរួមអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិកម្ពុជា និងទាមទារឱ្យមានការសហការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ។

ជាមួយនឹងសមិទ្ធផលដ៏ច្រើនតាមរយៈការវិនិយោគរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជំនាញលើហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍សមត្ថភាពគ្រូ ការកសាងកញ្ចប់ស្តង់បណ្តុះបណ្តាល និងកែទម្រង់ប្រព័ន្ធ អ.ប.វ. ក្នុងរយៈពេល៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសរុបចំនួន២៧៣ ១៩៤នាក់ (ស្ត្រី១២០ ១២៨នាក់), បានផ្តល់ការបណ្តុះបណ្តាលជំនាញឡើងវិញដល់កម្មករនិយោជិតដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ក្រោមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលសរុបចំនួន ១៤ ០០០នាក់, បានផ្តល់ឱកាសដល់ការហ្វឹកហ្វឺនកូនជាងចំនួន ១១៦ ៩៦៨នាក់ (ស្រី ៨៥ ៧១៥នាក់) និងការចុះកម្មសិក្សា/ទស្សនកិច្ចសិក្សានៅតាមរោងចក្រ សហគ្រាស ចំនួន ១៦ ១១៦នាក់ (ស្រី ៤ ១០៨នាក់), និងបានធ្វើតេស្តទទួលស្គាល់ការសិក្សាពីមុនចំនួន ១ ៣៩១នាក់ (ស្រី ៦៤នាក់)។

បើធៀបចំនួននេះទៅនឹងយុវជនដែលមានអាយុចាប់ពី១៥ឆ្នាំដែលចាកចេញពីការសិក្សាចំណោះទូទៅ និងបើសិក្សាលើកម្លាំងពលកម្មកំពុងស្ថិតក្នុងពិភពការងារបច្ចុប្បន្នដែលទទួលបានការបណ្តុះបណ្តាលជំនាញ គឺនៅមានចំនួនតិចតួចនៅឡើយ ដែលទាំងនេះបណ្តាលមកពីកម្មវិធីបណ្តុះបណ្តាលមិនទាន់មាន

ភាពសមស្របទាំងរយៈពេលវែងពេក និងមិនទាន់មានភាពទន់ភ្លន់ពេញលេញដែលសម្រួលដល់ការសិក្សាផងរៀនផង, គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅឆ្ងាយពីក្រុមគោលដៅដែលមានតម្រូវការបណ្តុះបណ្តាល, ពុំទាន់មានយន្តការសហការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពដើម្បីផ្សព្វផ្សាយ ផ្លាស់ប្តូរព័ត៌មាន និងជំរុញយុវជន; ការផ្តល់តម្លៃទៅលើបច្ចេកវិទ្យា ឬវិទ្យាសាស្ត្រសម្រាប់ការអនុវត្តផ្នត់គំនិតនៃការចាប់យកអាជីព ឬជំនាញពាក់ព័ន្ធ និងសារៈសំខាន់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅមិនទាន់បានសមស្របនៅឡើយ, គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារបានទាំងស្រុងនៅឡើយ ដោយកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពមិនទាន់បានឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម, ការអនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលមិនទាន់បានពេញលេញ, ចំនួនគ្រូ និងសមត្ថភាពគ្រូនៅមានកម្រិត, ការធានាគុណភាពនៃការបណ្តុះបណ្តាល នៅមិនទាន់គ្រប់ជ្រុងជ្រោយ; ការចូលរួមពីវិស័យឯកជន ក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យ អ.ប.វ. នៅមានកម្រិតនៅឡើយ, យន្តការប្រមូលផ្តុំមូលនិធិសម្រាប់ការអភិវឌ្ឍជំនាញនៅមិនទាន់គ្រប់ជ្រុងជ្រោយ, ការលើកកម្ពស់ការចុះកម្មវិធីសិក្សា កម្មវិធីហ្វឹកហ្វឺនកូនជាង ការផ្តល់ឱកាសការងារ និងបង្កើនឱកាសបណ្តុះបណ្តាលបង្កើនសមត្ថភាពកម្មករនិយោជិតនៅនឹងកន្លែងការងារនៅមានកម្រិត; នៅខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ រោងជាង និងបន្ទប់ពិសោធន៍ ឧបករណ៍បរិក្ខារ និងមិនទាន់សមស្របតាមតម្រូវការជាក់ស្តែងក្នុងការបណ្តុះបណ្តាល ជាពិសេសតាមជំនាញអាទិភាព; និងការសម្របសម្រួលពីគ្រប់ក្រសួងស្ថាប័នដែលផ្តល់សេវាការអប់រំបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រព័ន្ធព័ត៌មាន និងអភិបាលកិច្ចក្នុងប្រព័ន្ធ អ.ប.វ. ពុំទាន់បានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយនៅឡើយ។

ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមខាងលើ រួមជាមួយនឹងការប្រែប្រួលនៃរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ច ការផ្លាស់ប្តូរនៃពិភពការងារនិងបច្ចេកវិទ្យានៃទីផ្សារការងារ និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ និងដើម្បីឈានទៅសម្រេចគោលដៅចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ ចាំបាច់ត្រូវមានផែនទីមួយជាក់លាក់មួយដែលជាមាគ៌ាចង្អុលបង្ហាញផ្លូវការអភិវឌ្ឍមូលធនមនុស្ស ដើម្បីគាំទ្រការរីកចម្រើនសង្គមសេដ្ឋកិច្ចកម្ពុជា។

ហេតុដូចនេះផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជាឆ្នាំ២០២៣-២០៣៥ ត្រូវបានបង្កើតឡើង ធ្វើជាឯកសារយុទ្ធសាស្ត្រណែនាំដល់គ្រប់តួអង្គពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញ ចូលរួមពង្រឹងគុណភាពនៃការអភិវឌ្ឍជំនាញកម្ពុជាឱ្យមានលទ្ធភាពបំពេញសក្តានុពលនៃការរីកចម្រើននាពេលបច្ចុប្បន្ន និងពេលអនាគត ដើម្បីចូលរួមរក្សា និងជំរុញកំណើនសេដ្ឋកិច្ចជាតិក្នុងរយៈពេលខ្លី មធ្យម និងវែងក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព។ តួអង្គពាក់ព័ន្ធនីមួយៗនឹងរៀបចំ និងអនុវត្ត "ផែនការនិងយុទ្ធសាស្ត្រវិស័យជាក់លាក់" របស់ខ្លួនឆ្ពោះទៅរកការសម្រេចគោលបំណង និងគោលដៅ ដែលបាន

កំណត់នៅក្នុងផែនទីបង្ហាញផ្លូវនេះ។ ផែនទីបង្ហាញផ្លូវនេះ ត្រូវបានធ្វើឡើងឱ្យស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ និងគោលនយោបាយយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំផ្សេងៗរបស់កម្ពុជាដូចបានរៀបរាប់ខាងលើ។ លើសពីនេះទៀត ផែនទីបង្ហាញផ្លូវនេះមានរៀបរាប់ពីសកម្មភាពអន្តរាគមន៍ដែលកំណត់ពេលវេលា និងសូចនាករសមិទ្ធកម្មជាក់លាក់ដែលជាត្រីវិស័យសម្រាប់តួអង្គពាក់ព័ន្ធនឹង អ.ប.វ. ចូលរួមក្នុងការអភិវឌ្ឍជំនាញ។

## ផ្នែកទី២៖ អភិក្រមប្រើប្រាស់ក្នុងការរៀបចំផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ

ផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបចំឡើងជា៣ដំណាក់កាលដាច់ៗពីគ្នា ប៉ុន្តែមានភាពប្រទាក់ក្រឡាគ្នា មានដូចជាដំណាក់កាលរៀបចំនិងអភិវឌ្ឍ ដំណាក់កាលពិនិត្យឡើងវិញ និងដំណាក់កាលបញ្ចប់ដូចខាងក្រោម៖

*<u>ដ្យាក្រាមសង្ខេបស្តីពីដំណាក់កាលក្នុងការរៀបចំផែនទីបង្ហាញផ្លូវ</u>*

| ដំណាក់កាល | ដំណាក់កាលរៀបចំ និងអភិវឌ្ឍ | ដំណាក់កាលពិនិត្យឡើងវិញ | ដំណាក់កាលបញ្ចប់ |
|---|---|---|---|
| សកម្មភាព | • ការស្រាវជ្រាវដោយផ្អែកលើឯកសារ ដើម្បីយល់ដឹងអំពីប្រព័ន្ធ អ.ប.វ. កម្ពុជា<br>• សិក្សាស្រាវជ្រាវពីឧត្តមានុវត្តន៍អន្តរជាតិ នៃប្រទេសចំនួន ៦ ក្នុងការអភិវឌ្ឍប្រព័ន្ធ អ.ប.វ.<br>• កំណត់បញ្ហាប្រឈមនៃប្រព័ន្ធ អ.ប.វ.<br>• កំណត់រចនាសម្ព័ន្ធនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញឆ្នាំ ២០២២-២០៣៥<br>• រៀបចំសេចក្តីព្រាងបឋមនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ | • ផ្ញើសេចក្តីព្រាងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញទៅគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូល និងមតិយោបល់<br>• រៀបចំកិច្ចប្រជុំតាមរយៈប្រព័ន្ធវីដេអូពីចម្ងាយជាមួយក្រុមការងារ ADB និងតួអង្គពាក់ព័ន្ធនឹង អ.ប.វ. ដើម្បីប្រមូលធាតុចូល និងមតិយោបល់លើសេចក្តីព្រាងផែនទីបង្ហាញផ្លូវ | • កែសម្រួល និងរៀបចំសេចក្តីព្រាងចុងក្រោយនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញដោយផ្អែកលើធាតុចូល និងមតិយោបល់ដែលប្រមូលបាន<br>• បញ្ចប់សេចក្តីព្រាងផែនទីបង្ហាញផ្លូវ<br>• រៀបចំសិក្ខាសាលាពិនិត្យ និងពិភាក្សាចុងក្រោយដើម្បីស្នើសុំការឯកភាពគ្នាលើផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ<br>• ប្រជុំពិនិត្យ និងសម្រេចដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| លទ្ធផលក្នុងក្រុ | • សេចក្តីព្រាងបឋមនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ដោយបានកំណត់ក្របខណ្ឌពេលវេលា និងសកម្មភាពសម្រាប់អនុវត្ត | • កំណត់ហេតុកិច្ចប្រជុំជាមួយតួអង្គពាក់ព័ន្ធ (ធាតុចូល និងមតិយោបល់លើសេចក្តីព្រាងបឋមនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ | • ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជាត្រូវបានអនុម័តប្រើប្រាស់ជាផ្លូវការ |

- *ដំណាក់កាលរៀបចំ និងអភិវឌ្ឍ (Design and development phase)*៖ ដំណាក់កាលនេះចាប់ផ្តើមជាមួយនឹងការស្រាវជ្រាវលើឯកសារដែលមានស្រាប់យ៉ាងទូលំទូលាយអំពីឧត្តមានុវត្តន៍អន្តរជាតិអំពីរចនាសម្ព័ន្ធនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(អ.ប.វ.) ដែលផ្តោតលើ៖ ស្ថាប័នអនុវត្តសំខាន់ៗ, តួអង្គជំរុញ, អ្នកទទួលផល និងកំណត់រកនូវបញ្ហា និងការប្រឈមនៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ប្រទេសកម្ពុជា។ លើសពីនេះ ធាតុចូលពី

ការស្រាវជ្រាវបានផ្តល់ជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនេះព្រមទាំងការកំណត់ទិសដៅសម្រាប់អនុវត្តការងារក្នុងដំណាក់កាលបន្តបន្ទាប់។

- *ដំណាក់កាលពិនិត្យឡើងវិញ (Review phase)*៖ ដំណាក់កាលនេះផ្តោតលើការផ្សព្វផ្សាយសេចក្តីព្រាងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ ដែលបានរៀបចំនៅក្នុងដំណាក់កាលដំបូងដល់តួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីប្រមូលធាតុចូល និងមតិយោបល់ តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយ (ដោយសារត្រូវរក្សាវិធានសុខាភិបាលបង្ការជំងឺកូវីដ-១៩)។
- *ដំណាក់កាលបញ្ចប់ (Finalization phase)*៖ ដំណាក់កាលនេះត្រូវបានអនុវត្តក្នុងគោលបំណងរៀបចំសេចក្តីព្រាងចុងក្រោយនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ តាមរយៈធាតុចូល និងមតិយោបល់ទទួលបាននៅក្នុងដំណាក់កាលទី ២ បន្ទាប់ពីបានកែសម្រួលផ្អែកលើធាតុចូល និងមតិយោបល់ដែលប្រមូលបានពីតួអង្គពាក់ព័ន្ធទាំងអស់។ បន្ទាប់ពីបានកែសម្រួលរួចរាល់ សេចក្តីព្រាងនៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ ត្រូវបានដាក់ឆ្លងក្នុងកិច្ចប្រជុំពិភាក្សាចុងក្រោយដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងស្នើសុំការឯកភាពពីគ្រប់តួអង្គពាក់ព័ន្ធ និងបានប្រជុំអនុម័តឯកភាពពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជារួម ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ បានរៀបចំឡើងផ្អែកលើអភិក្រម Top-down និង Bottom-up ដើម្បីធានានូវតុល្យភាពរវាងគោលនយោបាយថ្នាក់ជាតិ និងរៀបចំកម្មវិធីដែលផ្តល់ការណែនាំជាក់លាក់សម្រាប់ការអភិវឌ្ឍជំនាញនៅក្នុងប្រទេស ក៏ដូចជាការព្រមទទួលស្គាល់នូវការពិត និងបញ្ហាប្រឈមគន្លឹះដែលកើតមានឡើងក្នុងប្រព័ន្ធអេកូឡូស៊ីនៃការអភិវឌ្ឍជំនាញកម្ពុជា។ ក្នុងន័យនេះ អភិក្រម Top-down និង Bottom-up ដាក់បញ្ចូលនូវការចូលរួមនិងតួនាទីរបស់ក្រសួង-ស្ថាប័នរដ្ឋ និងតួអង្គពាក់ព័ន្ធដទៃទៀតក្នុងការអភិវឌ្ឍជំនាញ តាមរយៈប្រជុំ សិក្ខាសាលាជាច្រើនដងដើម្បីពិគ្រោះយោបល់ ពិនិត្យផ្ទៀងផ្ទាត់ និងស្នើសុំការឯកភាពពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីទទួលបានការអនុម័តឯកភាពពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការៀបចំផែនទីង្ហាញផ្លូវនេះ។

ផែនទីបង្ហាញផ្លូវនេះផ្តោតសំខាន់លើលទ្ធផល បរិយាបន្ន ការអនុវត្ត និងសមិទ្ធកម្មនៃការអនុវត្តព្រមទាំងបានកំណត់នូវគោលដៅរយៈពេលខ្លី មធ្យម និងវែង សមស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលដែលមានចែងនៅក្នុង៖ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥, គោលនយោបាយជាតិស្តី

ពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣, គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត, ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង២០៥០, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ និងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ និងបានបន្សុីគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ (គោលដៅពាក់ព័ន្ធមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ)។

សូមបញ្ជាក់ជូនផងដែរថា ផ្នែកបន្ទាប់ក្នុងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនេះ នឹងលម្អិតអំពីសសរស្តម្ភគោលបំណងទាំង៥ និងគោលដៅគន្លឹះដែលផ្អែកលើចក្ខុវិស័យថ្នាក់ជាតិ គោលនយោបាយ និងឯកសារយុទ្ធសាស្ត្ររួមជាមួយសូចនាករសមិទ្ធកម្ម ក្របខណ្ឌពេលវេលា និងក្រសួងស្ថាប័ន ភ្នាក់ងារឬគណៈកម្មការអន្តរក្រសួងដែលទទួលបន្ទុកអនុវត្តស្របតាមគោលបំណងនីមួយៗ។

## ផ្នែកទី៣៖ ចក្ខុវិស័យ គោលបំណង គោលដៅនៃផែនទីបង្ហាញផ្លូវ

### ៣.១.ចក្ខុវិស័យ

ផែនទីបង្ហាញផ្លូវនេះមានចក្ខុវិស័យដើម្បីផលិត ឬប្រែក្លាយកម្លាំងពលកម្ម ឬធនធានមនុស្សកម្ពុជាជាធនធានជន្ទល់សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិដែលប្រកបដោយសមត្ថភាព និងផលិតភាពខ្ពស់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត និងផ្តល់ឱកាសទទួលបានការសិក្សាពេញមួយជីវិត និងធានាថាប្រជាពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត មានការងារធ្វើល្អសមរម្យ មានសេចក្តីថ្លៃថ្នូរ និងមានកម្រិតជីវភាពកាន់តែប្រសើរឡើង។

### ៣.២.គោលបំណង

ផែនទីបង្ហាញផ្លូវមានគោលបំណងពង្រឹងគុណភាពនៃការអភិវឌ្ឍជំនាញកម្ពុជាឱ្យមានលទ្ធភាពបំពេញសក្តានុពលនៃការរីកចម្រើននាពេលបច្ចុប្បន្ន និងអនាគត ដើម្បីរួមចំណែករក្សា និងជំរុញកំណើនសេដ្ឋកិច្ចជាតិក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព។

ដើម្បីសម្រេចបានគោលបំណងនេះ សសរស្តម្ភយុទ្ធសាស្ត្រចំនួន៥ ត្រូវបានកំណត់យ៉ាងច្បាស់ដែលប្រទាក់ក្រឡាគ្នាសំដៅលើការដោះស្រាយបញ្ហាប្រឈមនានានៃប្រព័ន្ធអេកូឡូសុីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់កម្ពុជា៖

**៣.២.១.ការពង្រឹងគុណភាព អ.ប.វ.៖** ការពង្រឹងគុណភាព អ.ប.វ. ឆ្ពោះទៅរកការផលិតនូវបណ្តុំកម្លាំងពលកម្មជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងបានត្រៀម

ខ្លួនរួចរាល់សម្រាប់ចូលឧស្សាហកម្មតាមរយៈការអនុវត្តពេញលេញនូវក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា, ការធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពដោយបញ្ចូលបន្ថែមជំនាញទន់ ជំនាញបច្ចេកវិទ្យាថ្មីៗ ឆ្លើយតបនឹងបដិវត្តឧស្សាកម្ម ៤.០ ជំនាញនាពេលអនាគត និងសេដ្ឋកិច្ចបៃតង, ការធ្វើឱ្យកម្មវិធីបណ្តុះបណ្តាលមានភាពទន់ភ្លន់, ការកសាងហេដ្ឋារចនាសម្ព័ន្ធបំពាក់ឧបករណ៍សម្ភារបណ្តុះបណ្តាល និងធ្វើបរិវត្តកម្មគ្រឹះស្ថានអ.ប.វ, ការធ្វើវិក្រឹត្យការ អធិការកិច្ច និងវាយតម្លៃសមត្ថភាពដើម្បីពង្រឹងគុណភាព និងសមត្ថភាពគ្រូបច្ចេកទេស, និងការបន្សីុគ្នានឹងក្របខ័ណ្ឌគុណវុឌ្ឍិយោងកម្រិតតំបន់ និងពង្រឹងក្រុមប្រឹក្សាអភិវឌ្ឍន៍ជំនាញដែលមានស្រាប់។

**៣.២.២.ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ៖** ការកសាងកិត្តិនាមនិងអត្តសញ្ញាណ និងបង្កើនការផ្សព្វផ្សាយគ្រប់ទម្រង់ឱ្យបានដល់សហគមន៍ដើម្បីបង្កើនភាពទាក់ទាញ ពង្រឹងការតម្រង់ទិសវិជ្ជាជីវៈ ដើម្បីបង្កើនការយល់ដឹង ផ្លាស់ប្តូរផ្នត់គំនិត ការផ្តល់តម្លៃនិងសារៈសំខាន់ជំរុញឱ្យមានក្តីស្រមៃ និងមោទកភាពក្នុងការចាប់យក អ.ប.វ.។ រៀបចំកម្មវិធី អ.ប.វ. ដោយបញ្ចូលនូវការលើកកម្ពស់សហគ្រិនភាព ឱកាសហិរញ្ញប្បទានកូនជាង និងប្រកបដោយបរិយាបន្នដែលមិនទុកនរណាម្នាក់ចោល ដោយបង្កលទ្ធភាពងាយស្រួលដល់ក្រុមងាយរងគ្រោះចូលមកសិក្សានៅផ្នែក អ.ប.វ.។

**៣.២.៣.អ.ប.វ. ដែលឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម៖** សំដៅដល់ការពង្រីកតួនាទី ភារកិច្ច និងការចូលរួមរបស់វិស័យឯកជននៅក្នុងការអភិវឌ្ឍជំនាញ ពង្រឹង និងពង្រីកបណ្តាញរវាងគ្រឹះស្ថានអ.ប.វ. និងឧស្សាហកម្ម, លើកកម្ពស់ការរៀបចំជំនាញឡើងវិញ (Reskilling) និងការបង្កើនជំនាញ (Upskilling) និងបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យបន្ថែមទៀត។

**៣.២.៤.អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ៖** ពង្រឹងអភិបាលកិច្ចប្រព័ន្ធ អ.ប.វ. ដោយបន្តអភិវឌ្ឍច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពង្រឹងយន្តការអន្តរស្ថាប័នដើម្បីជំរុញការត្រួតពិនិត្យនិងគ្រប់គ្រង។ ពង្រឹងប្រព័ន្ធធានាគុណភាព ពង្រឹងសមត្ថភាពគ្រប់គ្រងនិងដឹកនាំ និងការបង្កើតគណៈកម្មាធិការគ្រប់គ្រងនៅតាមគ្រឹះស្ថាន អ.ប.វ. ដើម្បីបង្កើនការទទួលខុសត្រូវ និងស្វយ័តភាព។ បង្កើតផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ អ.ប.វ. រួមទាំងអភិវឌ្ឍ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងការទទួលព័ត៌មានត្រឡប់ដើម្បីត្រួតពិនិត្យនិងវាយតម្លៃអភិបាលកិច្ចប្រព័ន្ធ អ.ប.វ.ប្រកបដោយប្រសិទ្ធភាព។

**៣.២.៥.ការផ្តល់ហិរញ្ញប្បទាន និងចីរភាព៖** ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន អ.ប.វ. និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដោយលើកកម្ពស់ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពនៃយន្តការផ្តល់ហិរញ្ញប្បទានដែលមានស្រាប់នៃមូលនិធិអភិវឌ្ឍន៍ជំនាញ, ពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ដោយឆ្ពោះទៅរកការអនុវត្តផ្អែកលើលទ្ធផល និងស្វ័យភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញ, បង្កើនការវិភាជន៍ថវិកាថ្នាក់ជាតិសម្រាប់ អ.ប.វ./ការអភិវឌ្ឍជំនាញ,

បង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងមូលនិធិដែលមានស្រាប់ពីដៃគូមានដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ វិស័យឯកជន និងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ។

*រូបភាពទិដ្ឋភាពទូទៅនៃសសរស្តម្ភយុទ្ធសាស្ត្រទាំង៥នៃផែនទីបង្ហាញផ្លូវ៖*




**ការពង្រឹងគុណភាព អ.ប.វ.**

ការពង្រឹងគុណភាព អ.ប.វ. ដើម្បីផលិតនូវបណ្តុំពលកម្មជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ/ឧស្សាហកម្មនាពេលបច្ចុប្បន្ន និងអនាគត។

**ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ**

ការកសាងកិត្តិនាមនិងអត្តសញ្ញាណ និងបង្កើនការផ្សព្វផ្សាយគ្រប់ទម្រង់ និងកម្មវិធីមិនទុកនរណាម្នាក់ចោល ដើម្បីបង្កើនភាពទាក់ទាញ ជំរុញឱ្យមានក្តីស្រមៃ និងមោទកភាពក្នុងការចាប់យក អ.ប.វ និងដើម្បីចូលរួមបង្កើនការចុះឈ្មោះចូលរៀន។

**អ.ប.វ. ឆ្លើយតបនឹងឧស្សាហកម្ម**

ការពង្រឹង និងពង្រីកកិច្ចសហការជាមួយវិស័យឯកជនជាពិសេសស ម្រាប់កិច្ចសហការយុរអង្វែងពេញវដ្តនៃប្រព័ន្ធធានាគុណភាព អ.ប.វ.។

**អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ**

ការពង្រឹងអភិបាលកិច្ច ពង្រឹងយន្តការស្ថាប័ននិងអន្តរស្ថាប័ន និងពង្រឹងប្រព័ន្ធធានាគុណភាព អ.ប.វ. និងការត្រួតពិនិត្យ និងវាយតម្លៃ។

**ការផ្តល់ហិរញ្ញប្បទាន និងចីរភាព**

ការធ្វើពិពិធកម្មប្រភពហិរញ្ញវត្ថុ បង្កើនទំហំថវិកាសម្រាប់ អ.ប.វ. ធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ។

## ៣.៣. គោលដៅ និងសូចនាករសមិទ្ធកម្មគន្លឹះ

ដើម្បីសម្រេចបាននូវសសរស្តម្ភយុទ្ធសាស្ត្រទាំង៥ខាងលើ ផែនទីបង្ហាញផ្លូវនេះមានគោលដៅសរុបចំនួន២៦ និងសមិទ្ធកម្មគន្លឹះសរុបចំនួន២៧ ដែលក្នុងនោះបានរៀបចំជាសកម្មភាពអន្តរាគមន៍ និងសូចនាករសមិទ្ធកម្មតាមអន្តរាគមន៍នីមួយៗចំនួន៧៥ (មានលម្អិតនៅផ្នែកទី៦) ដែលត្រូវបានរៀបចំឡើងប្រទាក់ក្រឡាគ្នាតាមសសរស្តម្ភយុទ្ធសាស្ត្រ និងគោលដៅនីមួយៗ៖

| លរ | សសរស្តម្ភ | គោលដៅ | សូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|---|---|
| ១. | ការពង្រឹងគុណភាព អ.ប.វ. | • ឆ្ពោះទៅរកការអនុវត្តពេញលេញនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា<br>• ការកែលម្អការកសាងសមត្ថភាពគ្រូបច្ចេកទេស<br>• ការអភិវឌ្ឍកញ្ចប់ម៉ូឌុលបណ្តុះបណ្តាលម៉ូឌុលសិក្សាតាមអនឡាញ ឬពីចម្ងាយ | • ចំនួនស្តង់ដាសមត្ថភាពដែលបានកំណត់នៅក្នុងឧស្សាហកម្មនីមួយៗ<br>• ចំនួនគ្រូឧទ្ទេសដែលបានបណ្តុះបណ្តាល<br>• ចំនួនសិស្ស-និស្សិត និងសិក្ខាកាមដែលបានបណ្តុះបណ្តាល<br>• ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលដែលបានកែលម្អ |

| លរ | សសរស្តម្ភ | គោលដៅ | សូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|---|---|
| | | និងការរួមបញ្ចូលជំនាញទន់នៅក្នុងកម្មវិធី អ.ប.វ. ទាំងអស់<br>• ការធ្វើបរិវត្តកម្មប្រែក្លាយគ្រឹះស្ថាន អ.ប.វ. (តាមរយៈការកែលម្អបរិក្ខារូបវ័ន្តបណ្តុះបណ្តាលដោយយកចិត្តទុកដាក់ដល់យេនឌ័រ និងការរៀបចំ ដែលសន្សំសំចៃថាមពល) និងប្រែក្លាយស្ថានភាពបច្ចុប្បន្នរបស់ពួកគេ អាចបំពេញមុខងារជាគ្រឹះស្ថានអ.ប.វ. ភូមិភាគ<br>• ការផ្តល់ការបណ្តុះបណ្តាលជំនាញសម្រាប់តម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគតរួមមានបដិវត្តន៍ឧស្សាហកម្ម ៤.០ និងសេដ្ឋកិច្ចបៃតង<br>• ការពង្រឹងក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានស្រាប់<br>• ការរៀបចំអភិក្រមសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈថ្មីដែលរួមបញ្ចូលការអប់រំនិងជំនាញ | • ចំនួនវគ្គបណ្តុះបណ្តាលកម្រិតខ្ពស់ដែលបានបង្កើតនិងអនុវត្ត<br>• ចំនួនស្តង់ដាសមត្ថភាពតាមមុខរបរដែលបានបង្កើតឡើងសម្រាប់បដិវត្តន៍ឧស្សាហកម្ម ៤.០ និងសេដ្ឋកិច្ចបៃតង<br>• ចំនួនក្រុមប្រឹក្សាជំនាញតាមវិស័យដែលបានពង្រឹង<br>• គោលនយោបាយអប់រំថ្មីដែលរួមបញ្ចូលការអប់រំ និងជំនាញ |
| ២. | **ការពង្រឹងកិត្តិនាម និងការផ្សព្វផ្សាយ** | • ការបង្កើនការចូលរួមនិងការយល់ដឹងអំពីការបណ្តុះបណ្តាលជំនាញ<br>• ការផ្តោតលើការកសាងកិត្តិនាម ការប្រឹក្សាយោបល់ និងការធ្វើការផ្សព្វផ្សាយជំនាញ (Skill Advocacy)<br>• ការកែលម្អច្រកបង្កើនលទ្ធភាពចូលសិក្សា ដល់ក្រុមដែលបាត់បង់ឱកាស<br>• ការលើកកម្ពស់សហគ្រិនភាព<br>• ការផ្តល់ឱកាសការហ្វឹកហ្វឺនកូនជាង (Apprenticeship) សម្រាប់ការងារ | • បង្កើតយុទ្ធសាស្ត្រកសាងកិត្តិនាមសម្រាប់ "ជំនាញនៅកម្ពុជា"<br>• ភាគរយនៃកំណើនសិស្សបានចុះឈ្មោះកើនឡើង<br>• ភាគរយនៃកំណើនការងារសម្រាប់សិស្សបញ្ចប់ការសិក្សាពី អ.ប.វ.កើនឡើង<br>• ភាគរយនៃកំណើនការចុះឈ្មោះចូលរៀនរបស់ក្រុមជនងាយរងគ្រោះកើនឡើង<br>• ភាគរយនៃកំណើនបេក្ខជនដែលក្លាយជាសហគ្រិនកើនឡើង<br>• ភាគរយនៃកំណើនការហ្វឹកហ្វឺនកូនជាងសម្រាប់សិស្សបញ្ចប់ការសិក្សា អ.ប.វ. កើនឡើង |

| ល.រ | សសរស្តម្ភ | គោលដៅ | សូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|---|---|
| ៣. | **អ.ប.វ. ឆ្លើយតបនឹងឧស្សាហកម្ម** | • ការលើកកម្ពស់តួនាទី និងការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍជំនាញ<br>• ការពង្រឹងការផ្សារភ្ជាប់គ្នារវាងគ្រឹះស្ថាន អ.ប.វ. និងឧស្សាហកម្ម<br>• ការលើកកម្ពស់ការកសាងជំនាញឡើងវិញ (Reskilling) និងការបង្កើនជំនាញ (Upskilling)<br>• ការបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យបន្ថែមទៀត | • ចំនួនកម្មវិធីភាពជាដៃគូឧស្សាហកម្ម ដែលត្រូវបានអនុវត្ត<br>• ចំនួនកន្លែងការងារនៅឧស្សាហកម្មដែលទទួលបានជោគជ័យរួមមានការចុះកម្មសិក្សា និងហ្វឹកហ្វឺនកូនជាង<br>• ភាគរយនៃកំណើនការងារយុវជនកើនឡើង<br>• ភាគរយនៃកម្លាំងពលកម្មដែលមានស្រាប់បានបង្កើនជំនាញ ឬបណ្តុះជំនាញថ្មី/ ឆ្លង-កាត់កម្មវិធីសិក្សាផ្អែកលើការងារ<br>• ចំនួនក្រុមប្រឹក្សាជំនាញតាមវិស័យថ្មីៗត្រូវបានបង្កើតនិងដំណើរការ |
| ៤. | **អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ** | • ការបង្កើនប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ/យន្តការស្ថាប័នរបស់ អ.ប.វ.<br>• ការធ្វើឱ្យប្រសើរឡើងនូវការរួមបញ្ចូលគ្នា និងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងគ្រប់តួអង្គពាក់ព័ន្ធនៃប្រព័ន្ធ អ.ប.វ.<br>• ការបង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព<br>• ការពង្រឹងប្រសិទ្ធភាពទិន្នន័យសម្រាប់ការធ្វើផែនការនិងការសម្រេចចិត្ត<br>• ការលើកកម្ពស់គណនេយ្យភាព និងការផ្តល់ស្វ័យភាពដល់គ្រឹះស្ថាន អ.ប.វ.<br>• ការបង្កើតផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍ អ.ប.វ. - ក្រុមផ្តល់យោបល់សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតួអង្គពាក់ព័ន្ធផ្សេងទៀតសម្រាប់ អ.ប.វ. | • សមាសភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាលត្រូវបានធ្វើបច្ចុប្បន្នភាព<br>• ការកំណត់សូចនាករដែលអាចក្តោបលើមុខងារនៃប្រព័ន្ធអេកូ អ.ប.វ. និងកំណត់របៀបវារៈសម្រាប់ការអភិវឌ្ឍជំនាញឆ្លើយតបនឹងគោលនយោបាយពាក់ព័ន្ធ<br>• ចំនួននៃភាពមិនចុះសម្រុងផ្នែកគោលនយោបាយរបស់អន្តរក្រសួង/ស្ថាប័ន ត្រូវបានកំណត់ និងដោះស្រាយ<br>• ប្រព័ន្ធនិងដំណើរការត្រួតពិនិត្យ និងវាយ-តម្លៃត្រូវបានបង្កើតឡើង<br>• ចំនួនស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើង |
| ៥. | **ការផ្តល់ហិរញ្ញ-ប្បទាន និងចីរភាព** | • លើកកម្ពស់ប្រសិទ្ធផល (ផលិត-ភាព) និងស័ក្តិសិទ្ធិភាព (បច្ច័យ) នៃយន្តការផ្តល់មូលនិធិដែលមានស្រាប់របស់មូលនិធិអភិវឌ្ឍន៍ជំនាញ | • ការផ្តល់មូលនិធិត្រូវបានផ្សារភ្ជាប់ទៅនឹងលទ្ធផលចុងក្រោយនៃគម្រោង/កម្មវិធី<br>• បង្កើតសូចនាករវាស់វែងលើភាពជោគជ័យនៃការអនុវត្តមូលនិធិអភិវឌ្ឍន៍ជំនាញ |

| លរ | សសរស្តម្ភ | គោលដៅ | សូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|---|---|
| | | • ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមគ្រឹះស្ថាន អ.ប.វ. សាធារណៈ ឆ្ពោះទៅរកការអនុវត្តផ្អែកលើលទ្ធផល និងស្វ័យភាព<br>• ការបង្កើនការបែងចែកថវិកាជាតិសម្រាប់ អ.ប.វ./ការអភិវឌ្ឍជំនាញ<br>• ការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធ និងមូលនិធិដែលមានស្រាប់ពីដៃគូដូចជាអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ វិស័យឯកជន។ល។ | • ការរួមបញ្ចូលគ្នានូវកម្មវិធី/គម្រោងផ្សេងៗ |

## ផ្នែកទី៤៖ តួនាទីរបស់តួអង្គពាក់ព័ន្ធសំខាន់ៗ

សសរស្តម្ភយុទ្ធសាស្ត្រនីមួយៗក្នុងផែនទីបង្ហាញផ្លូវអាចសម្រេចបានតាមរយៈការចូលរួមចំណែក និងការចូលរួមរបស់តួអង្គពាក់ព័ន្ធសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ី អ.ប.វ. នៅកម្ពុជា ដែលធ្វើការសម្របសម្រួល និងអភិបាលកិច្ចដោយ គ.ជ.ប.ប. ដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាសេនាធិការ។ តារាងខាងក្រោមបង្ហាញពីតួនាទីរបស់រាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ វិស័យឯកជន (ឧស្សាហកម្មនិងនិយោជក) អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានបណ្តុះបណ្តាល សហគមន៍ (ទីប្រឹក្សាអាជីព អ្នកសិក្សា ឪពុកម្តាយ និងគ្រូបង្រៀន) អង្គការមិនមែនរដ្ឋាភិបាល និងអង្គការជាតិនិងអន្តរជាតិក្នុងការកសាងប្រព័ន្ធអេកូឡូស៊ី អ.ប.វ. ជុំវិញសសរស្តម្ភទាំង៥ នៃផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញ។

| ល.រ | សសរស្តម្ភ | តួនាទីរបស់តួអង្គពាក់ព័ន្ធ |
|---|---|---|
| ១. | ការពង្រឹងគុណភាព អ.ប.វ. | **រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ**<br>• ជំរុញអន្តរាគមន៍តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការដឹកនាំដែលមានការចូលរួមពីតំណាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឧស្សាហកម្ម និយោជក និងនិយោជិត<br>• ដើរតួជាអ្នកគ្រប់គ្រងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាដើម្បីធានាបាននូវអនុលោមភាព ការដាក់ឱ្យអនុវត្ត និងការត្រួតពិនិត្យជាប្រចាំ។<br>**វិស័យឯកជន** |

| ល.រ | សសរស្តម្ភ | តួនាទីរបស់តួអង្គពាក់ព័ន្ធ |
|---|---|---|
| | | • ផ្តល់នូវធាតុចូលខាងផ្នែកតម្រូវការក្នុងការអភិវឌ្ឍគុណវុឌ្ឍិ និងស្តង់ដា ដោយមានតំណាងពីថ្នាក់ដឹកនាំក្នុងវិស័យឧស្សាហកម្ម, សហព័ន្ធនិយោជក, ក្រុមអ្នកផ្តល់យោបល់ ដើម្បីធានាបាននូវភាពបន្សីគ្នាទៅនឹងឧស្សាហកម្ម។<br>**អ្នកផ្តល់ការបណ្តុះបណ្តាល, គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល**<br>• ផ្តល់នូវធាតុចូលពីផ្នែកផ្តត់ផ្តង់លើការជំរុញលើកទឹកចិត្តអ្នកចូលរួមកម្មវិធីបណ្តុះបណ្តាលនៅគ្រប់ក្រុមគោលដៅផ្សេងៗគ្នាដូចជាស្រ្តី ក្រុមងាយរងគ្រោះ និងសិស្សបោះបង់ការសិក្សា។ល។<br>**សហគមន៍**<br>• កែសម្រួល អ.ប.វ. ឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមសហគមន៍ដើម្បីធានាគុណភាព អ.ប.វ. ដែលកំពុងត្រូវបានអនុវត្ត និងអនុលោមតាមគោលការណ៍ណែនាំ និងក្របខ័ណ្ឌចាំបាច់ទាំងអស់<br>• ផ្តល់ធាតុចូល និងមតិយោបល់លើស្តង់ដាមុខរបរ និងគំរូកម្មវិធីសិក្សាដែលបានរៀបចំ<br>• ផ្តល់ធាតុចូលអំពីក្តីរំពឹងរបស់អ្នកសិក្សា បញ្ហាក្នុងតំបន់ និងបញ្ហាផ្សេងៗ (សង្គម សេដ្ឋកិច្ច និងការអប់រំ) សម្រាប់ការបណ្តុះបណ្តាលដែលផ្អែកលើតម្រូវការ<br>• រៀបចំសិក្ខាសាលាផ្សព្វផ្សាយការយល់ដឹង និងពិគ្រោះយោបល់ជាប្រចាំដើម្បីពិភាក្សាអំពីនិន្នាការថ្មីៗ និងកំណែទម្រង់<br>• ផ្តល់មតិយោបល់ឱ្យបានទាន់ពេលវេលាលើគុណភាពនៃការបណ្តុះបណ្តាល។<br>**អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ**<br>• គាំទ្ររាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ ដើម្បីបន្សីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាជាមួយនឹងអន្តរជាតិ និងចែករំលែកនូវឧត្តមានុវត្តន៍អន្តរជាតិសម្រាប់ការអភិវឌ្ឍគុណភាព អ.ប.វ.<br>• ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសលើការបណ្តុះបណ្តាលយុទ្ធសាស្រ្ត និងរៀបចំតំឡើងឧបករណ៍សម្ភារ និងបច្ចេកវិទ្យាសំខាន់ៗ។ |
| ២. | ការលើកកម្ពស់កិត្តិនាម និងការផ្សព្វផ្សាយ | **រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ**<br>• ដើរតួនាទីជាអ្នកដឹកនាំក្នុងការផ្តល់ទិសដៅកសាងកិត្តិនាមស្របគ្នាទៅតាមយុទ្ធសាស្រ្ត និងផែនការជាតិដទៃទៀត<br>• សម្របសម្រួលជាមួយតួអង្គពាក់ព័ន្ធ (ឧស្សាហកម្ម និងស្ថាប័ន) ដើម្បីអប់រំ និងពង្រឹងការអនុវត្តតាមយុទ្ធសាស្រ្តកសាងកិត្តិនាម<br>• បង្កើតគោលនយោបាយ និងកម្មវិធីលើកកម្ពស់លទ្ធភាពទទួលបានការបណ្តុះបណ្តាលរបស់ក្រុមងាយរងគ្រោះ និងលើកកម្ពស់សហគ្រិនភាព។<br>**វិស័យឯកជន** |

| ល.រ | សសរស្តម្ភ | តួនាទីរបស់តួអង្គពាក់ព័ន្ធ |
| --- | --- | --- |
| | | • គាំទ្រយុទ្ធនាការកសាងកិត្តិនាមដោយផ្តល់នូវការករណីសិក្សាពាក់ព័ន្ធ និងបទពិសោធន៍ជោគជ័យនៃភាពជាដៃគូជាមួយឧស្សាហកម្ម<br>• ផ្តល់ការណែនាំ និងឱកាសសម្រាប់ការអភិវឌ្ឍសហគ្រិនភាព ការហ្វឹកហ្វឺនកូនជាង។ល។<br>**អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល**<br>• ធានាបាននូវការអនុវត្តយុទ្ធសាស្ត្រកសាងកិត្តិនាមទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព និងការប្រើប្រាស់សម្ភារអប់រំផ្សព្វផ្សាយ<br>• ទាក់ទាញសិស្សឱ្យចូលរួមតាមរយៈការប្រើប្រាស់សារត្រឹមត្រូវ ដើម្បីជំរុញភាពជឿជាក់លើខ្លួនឯងរបស់សិស្ស និងការកសាងកេរ្តិ៍ឈ្មោះរបស់ អ.ប.វ.<br>**សហគមន៍**<br>• ធានាថាបេក្ខជនយល់ដឹងពីអត្ថប្រយោជន៍របស់ អ.ប.វ. និងវិធីគាំទ្រពួកគេក្នុងការអភិវឌ្ឍអាជីព<br>• កំណត់អត្តសញ្ញាណអ្នកទទួលផល និងធ្វើឱ្យសហគមន៍មានការយល់ដឹងពីគម្រោង និងកម្មវិធី អ.ប.វ.នានា នៅថ្នាក់តំបន់/ថ្នាក់ខេត្ត<br>• ជួយកសាងមុខមាត់នៃប្រព័ន្ធអេកូឡូស៊ី អ.ប.វ. កម្ពុជាឱ្យក្លាយជាកម្រិតសកលដើម្បីបង្កើតសេចក្តីប្រាថ្នាផ្នែកជំនាញ។<br>**អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ**<br>• ផ្តល់ការគាំទ្រដល់យុទ្ធនាការទីផ្សារតាមរយៈការបង្កើនទម្រង់នៃ "ជំនាញកម្ពុជាដែលមានគុណប្រយោជន៍" ជាមួយនឹងភាពជាដៃគូអន្តរជាតិ, ការចូលរួមរបស់ភ្នាក់ងារផ្សព្វផ្សាយ និងការផ្សព្វផ្សាយជាសាធារណៈស្របទៅតាមយុទ្ធសាស្ត្រជាតិកសាងកិត្តិនាម។ |
| ៣. | អ.ប.វ. ឆ្លើយតបនឹងឧស្សាហកម្ម | **រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ**<br>• អនុវត្តគោលនយោបាយ និងការលើកទឹកចិត្ត (ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ) ដើម្បីលើកទឹកចិត្តដល់កម្មវិធីភាពជាដៃគូផ្នែកលើតម្រូវការឧស្សាហកម្ម<br>• ផ្តល់នូវសេវាកម្មផ្គូផ្គងការងារប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាយក្នុងការស្វែងរកការងារ និងភាពអត់ការងារធ្វើរយៈពេលវែង (ច្រើនជាង៦ខែ)។<br>**វិស័យឯកជន**<br>• ដើរតួជាភ្នាក់ងារដើម្បីទទួលស្គាល់ការបណ្តុះបណ្តាលជំនាញ និងការចំណាយដើម្បីប្រមូលផ្តុំកម្លាំងពលកម្មជំនាញ<br>• ចូលរួមយ៉ាងសកម្មតាមរយៈការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នានៅគ្រប់ដំណាក់នៃការបណ្តុះបណ្តាលដូចជាការអភិវឌ្ឍ |

| ល.រ | សសរស្តម្ភ | តួនាទីរបស់តួអង្គពាក់ព័ន្ធ |
| --- | --- | --- |
| | | កម្មវិធីសិក្សា, បាឋកថារបស់វាគ្មិន, ការប្រឹក្សាយោបល់, ការបណ្តុះបណ្តាលដោយការបំពេញការងារផ្ទាល់ និងការផ្តល់ការងារ។ល។<br>• ធ្វើបច្ចុប្បន្នភាពគ្រឹះស្ថានបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍចុងក្រោយលើការគ្រប់គ្រងធនធានមនុស្ស និងទំនាក់ទំនងឧស្សាហកម្ម។<br>**អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល**<br>• ដឹកនាំគម្រោង និងកម្មវិធីភាពជាដៃគូឧស្សាហកម្ម<br>• ធ្វើការជាមួយឧស្សាហកម្មដើម្បីបង្កើតក្របខ័ណ្ឌជំនាញជាទីទុកចិត្តដែលសិក្ខាកាមអាចកំណត់បានជាមួយនិយោជក។<br>**សហគមន៍**<br>• ការចូលរួមយ៉ាងសកម្មពីសហគមន៍ក្នុងការរៀបចំបង្កើតភាពជាដៃគូ<br>• ផ្តល់ជូននូវធនធាន និងការផ្សារភ្ជាប់ (ផ្តោតលើអាជីវកម្មក្នុងមូលដ្ឋាន) ទៅនឹងគ្រឹះស្ថាន អ.ប.វ.។<br>**អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ**<br>• អនុម័តគម្រោង និងកម្មវិធីសាកល្បងភាពជាដៃគូឧស្សាហកម្មឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ សកម្មភាពនេះនឹងផ្តល់នូវកម្លាំងរុញច្រាន និងនិចលភាពចាំបាច់<br>• ផ្តល់នូវការយល់ដឹងពាក់ព័ន្ធលើការផ្លាស់ប្តូរឧស្សាហកម្មនិងទិដ្ឋភាពសេដ្ឋកិច្ចសកល ឬក្នុងតំបន់ដែលជះឥទ្ធិពលដល់តួនាទី និងភាពសមស្របរបស់កម្ពុជា។ |
| ៤. | អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ | **រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ**<br>• រៀបចំ និងអនុវត្តការបង្កើតក្រុមប្រឹក្សាជំនាញខ្ពស់បំផុត ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធសំខាន់ៗ (ឧ. អ្នកដឹកនាំឧស្សាហកម្មគន្លឹះ អ្នកសិក្សា និងក្រុមអ្នកផ្តល់យោបល់។)<br>• សម្របសម្រួលការប្រជុំក្រុមប្រឹក្សាដើម្បីកំណត់ និងដោះស្រាយបញ្ហាគោលនយោបាយ និងភាពមិនប្រទាក់ក្រឡាគ្នានៃអន្តរក្រសួង/ស្ថាប័ននានា។<br>**វិស័យឯកជន**<br>• ចូលរួមក្នុងនាមជាតួអង្គពាក់ព័ន្ធសំខាន់ (តំណាងឱ្យឧស្សាហកម្ម និងនិយោជិក) ក្នុងការធានានូវភាពជោគជ័យនៃប្រព័ន្ធអភិបាលកិច្ចដែលបង្កើតឡើងសម្រាប់ប្រព័ន្ធអេកូឡូស៊ី អ.ប.វ.<br>• ចូលរួមចំណែកក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីតាមរយៈការស្រាវជ្រាវ និងការអភិវឌ្ឍ។<br>**អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល** |

| ល.រ | សសរស្តម្ភ | តួនាទីរបស់តួអង្គពាក់ព័ន្ធ |
|---|---|---|
| | | • ដើរតួជាអ្នកពាក់ព័ន្ធនៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ច អ.ប.វ. ដែលមានស្រាប់ ដើម្បីជំនួយក្នុងការការសម្របសម្រួលនិងតម្រង់ទិសដៅគោលនយោបាយ<br>• ផ្តល់នូវការគាំទ្រក្នុងការធ្វើសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍នៅកម្ពុជា (ផ្តោតលើឥទ្ធិពលនៃការវាយតម្លៃលើកម្មវិធីអភិវឌ្ឍន៍ជំនាញដែលមានស្រាប់ និងរៀបចំនូវរបាយការណ៍នៃរបកគំហើញក្នុងការស្រាវជ្រាវ "សៀវភៅស" (White Papers) ដើម្បីអភិវឌ្ឍ អ.ប.វ.)។<br>**សហគមន៍**<br>• ការចូលរួមយ៉ាងសកម្មរបស់សង្គមស៊ីវិល និងដៃគូសង្គមក្នុងគោលនយោបាយ និងការសម្រេចចិត្តក្នុងបរិបទទូលំទូលាយនៃការផ្លាស់ប្តូរគំរូពីលំនាំគ្រប់គ្រងបែបប្រពៃណីទៅជាលក្ខណៈពហុតួអង្គពាក់ព័ន្ធនៃគោលគំនិតអភិបាលកិច្ច។<br>**អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ**<br>• ផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធីពាក់ព័ន្ធដែលបង្កើតលទ្ធផល និងបច្ច័យត្រឹមត្រូវ<br>• ផ្តល់នូវការយល់ដឹងពាក់ព័ន្ធលើការផ្លាស់ប្តូរក្នុងឧស្សាហកម្មនិងសេដ្ឋកិច្ចសកល ឬក្នុងតំបន់ដែលជះឥទ្ធិពលដល់តួនាទី និងភាពសមស្របរបស់កម្ពុជា<br>• រៀបចំវេទិកាសម្រាប់កិច្ចសហការអន្តរជាតិដើម្បីពង្រឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅក្នុងវិស័យនេះ។ |
| ៥. | ការផ្តល់ហិរញ្ញប្បទាន និងចីរភាព | **រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ**<br>• រៀបចំក្របខ័ណ្ឌគោលនយោបាយនិងធ្វើការសម្រេចចិត្តលើយន្តការផ្តល់មូលនិធិ ដែលរួមមាន ការលើកទឹកចិត្តផ្នែកពន្ធ។ កម្មវិធី/គម្រោងផ្សេងៗគ្នាអាចប្រើការលើកទឹកចិត្តផ្សេងៗគ្នា (ហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ)។<br>**វិស័យឯកជន**<br>• ដើរតួជាម្ចាស់គម្រោង/កម្មវិធី ដើម្បីធានានូវការអនុវត្តប្រកបដោយជោគជ័យ<br>• ទទួលខុសត្រូវចំពោះការអនុវត្តសូចនាករដែលបានកំណត់ និងឯកភាពគ្នាសម្រាប់គម្រោង/កម្មវិធីផ្សេងៗ។<br>**អ្នកផ្តល់ការបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ/បណ្តុះបណ្តាល**<br>• ផ្តល់នូវទម្រង់ចំណូល និងចំណាយដើម្បីផ្តល់សក្តានុពលសម្រាប់និរន្តរភាពផ្នែកហិរញ្ញវត្ថុ<br>• តាមដានការប្រើប្រាស់ថវិកាតាមសូចនាករ និងពេលវេលាដែលបានឯកភាពគ្នា។ |

| ល.រ | សសរស្តម្ភ | តួនាទីរបស់តួអង្គពាក់ព័ន្ធ |
|---|---|---|
| | | **សហគមន៍**<br>• គាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រឹះស្ថាន អ.ប.វ. ដើម្បីលើកកម្ពស់លទ្ធភាពទទួលបាន និងការផ្សព្វផ្សាយ ។<br>• ដើរតួជាអ្នកពាក់ព័ន្ធដ៏សំខាន់ក្នុងការត្រួតពិនិត្យលើការប្រើប្រាស់មូលនិធិ អ.ប.វ.។<br>**អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ**<br>• ផ្តល់ហិរញ្ញប្បទានបន្ថែមដល់គម្រោង/កម្មវិធីពាក់ព័ន្ធដែលបង្កើតនូវលទ្ធ-ផល និងផលជះត្រឹមត្រូវ។ |

## ផ្នែកទី៥៖ ការតាមដាន និងវាយតម្លៃ

ប្រព័ន្ធតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព គឺជាមូលដ្ឋានគន្លឹះសម្រាប់ការរៀបចំផែនការ និងការសម្រេចចិត្តដោយផ្អែកលើភ័ស្តុតាង ហើយដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ។ ការតាមដាន និងវាយតម្លៃដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល (គ.ជ.ប.ប) ដោយមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាសេនាធិការ ត្រូវរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពជាប្រចាំអំពី "សកម្មភាពដែលបានអនុវត្ត និងសកម្មភាពដែលមិនអាចអនុវត្តទាន់ពេលវេលា" ដែលនេះមានសារៈសំខាន់ណាស់ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងការសិក្សាលើបរិបទគម្រោង។ របាយការណ៍នៃការតាមដាន និងវាយតម្លៃ ត្រូវធ្វើជាទៀងទាត់ ជាប្រចាំឆ្នាំ និងជារៀងរាល់កំឡុង ៣ឆ្នាំម្តង ដើម្បីកែសម្រួលគោលដៅ អន្តរាគមន៍ និងសូចនាករសមិទ្ធកម្មទៅតាមតម្រូវការជាក់ស្តែង ហើយឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់ការតាមដាន និងវាយតម្លៃនឹងត្រូវបានបង្កើតឡើងសម្រាប់សូចនាករនីមួយៗ ដើម្បីធានាភាពច្បាស់លាស់។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តវិស័យ អ.ប.វ. តាមបែបឌីជីថលត្រូវបានបង្កើតឡើង ដើម្បីសម្រួលការក្តោបយកនូវវឌ្ឍនភាពតាមសសរស្តម្ភយុទ្ធសាស្ត្រគោលដៅ អន្តរាគមន៍ និងសូចនាករសមិទ្ធកម្មដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវនេះ ក្នុងនោះច្រកជំនាញជាតិ (National Skills Portal) នឹងត្រូវបានបង្កើតឡើងដោយរួមបញ្ចូលតួអង្គពាក់ព័ន្ធចំនួន៣៖ គ្រឹះស្ថាន អ.ប.វ. ឧស្សាហកម្ម និងជនគ្មានការងារឬកំពុងស្វែងរកការបណ្តុះបណ្តាល។ តាមរយៈច្រកជំនាញជាតិ គ្រឹះស្ថានឧស្សាហកម្មនឹងត្រូវផ្តល់ព័ត៌មានអំពីតម្រូវការជំនាញ ចំណែកឯគ្រឹះស្ថាន អ.ប.វ. ត្រូវផ្តល់ព័ត៌មាន និងការចុះឈ្មោះសម្រាប់ការបណ្តុះបណ្តាល ដោយឡែកជនគ្មានការងារធ្វើ និងអ្នកកំពុងស្វែងរកការបណ្តុះបណ្តាលនឹងទទួលបានព័ត៌មានអំពីតម្រូវការ និងការបណ្តុះបណ្តា

លសម្រាប់ពួកគេ។ ច្រកជំនាញជាតិនឹងរួមបញ្ចូលនូវលទ្ធផលការបណ្តុះបណ្តាលតាមពេលវេលាជាក់លាក់ នឹងអាចធ្វើការវាយតម្លៃលើបញ្ហាប្រឈមនានា និងអាចបង្កើតយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យតាមតម្រូវការដោយងាយស្រួល។

## ផ្នែកទី៦៖ តារាងលម្អិតអន្តរាគមន៍ និងសូចនាករសមិទ្ធកម្ម តាមគោលដៅ និងសសរស្តម្ភ

នៅក្នុងតារាងខាងក្រោម នឹងលម្អិតពីអន្តរាគមន៍ និងសូចនាករសមិទ្ធកម្មតាមគោលដៅ និងគោលបំណងនៃសសរស្តម្ភយុទ្ធសាស្ត្រទាំង៥ ដែលមានពេលវេលាកំណត់ជាក់លាក់ និងក្រសួង/ស្ថាប័នទទួលខុសត្រូវ៖

- សូចនាករសមិទ្ធកម្ម៖ វាស់វែងភាពជោគជ័យនៃអន្តរាគមន៍
- សូចនាករឆ្នាំមូលដ្ឋាន៖ វឌ្ឍនភាពដែលសម្រេចបាននៅឆ្នាំ២០២១ ប្រសិនបើអន្តរាគមន៍បានអនុវត្តរួចហើយនៅក្នុងប្រព័ន្ធអេកូឡូស៊ី អ.ប.វ. បច្ចុប្បន្នក្នុងកម្មវិធី/គម្រោងណាមួយ
- សូចនាករគោលដៅ៖ គោលដៅដែលត្រូវសម្រេចសម្រាប់អន្តរាគមន៍ក្នុងរយៈពេលខ្លី មធ្យម និងវែង
- ក្រសួង/ស្ថាប័នទទួលខុសត្រូវ៖ ក្រសួង/អង្គការ/ស្ថាប័នដែលទទួលខុសត្រូវចំពោះអន្តរាគមន៍
- ភាពស្របគ្នានឹងយុទ្ធសាស្ត្រ៖ គោលនយោបាយនានា/គោលនយោបាយដែលកំពុងនៅជាធរមានទាំងឡាយណាដែលអន្តរាគមន៍បានបន្សុីជាមួយ
- ភាពស្របគ្នានឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលអន្តរាគមន៍នឹងចូលរួមចំណែក

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| **១. ការពង្រឹងគុណភាព អ.ប.វ.** | | | | | | | | | |
| **១.១. ការឆ្ពោះទៅរកការអនុវត្តពេញលេញនូវក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា** | | | | | | | | | |
| ១.១.១ | បង្កើតក្របខ័ណ្ឌរួមមួយដែលជាការណែនាំ/ដំណើរការជាជំហានៗ ដើម្បីអភិវឌ្ឍ កែសម្រួលឡើងវិញ និងការអនុម័តកញ្ចប់ស្តង់ដាជាតិតាមមុខរបរ/គុណវុឌ្ឍិ | ការអនុលោមតាមក្របខ័ណ្ឌ នៅតាម ក្រុមប្រឹក្សាជំនាញតាមវិស័យទាំងអស់ | គ្មានទិន្នន័យគោល | ក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានស្រាប់ទាំងបួន | ការអនុលោមតាម ក្រុមប្រឹក្សាជំនាញតាមវិស័យផ្សេងទៀត និងនៅពេលដែលវាត្រូវបានបង្កើតឡើង | | ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលមានការគាំទ្រពីអគ្គនាយកដ្ឋាន អ.ប.វ. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ក.ប.) | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |
| ១.១.២ | បង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍ កម្មវិធីសិក្សា ជាឯកសារជាក់លាក់ដែលបង្ហាញពីប៉ារ៉ាម៉ែត្រដើម្បីជួយក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងកំណត់លទ្ធផលនៃការសិក្សា | ការអនុលោមតាមក្របខ័ណ្ឌអភិវឌ្ឍន៍កម្មវិធីសិក្សានៅតាមក្រុមប្រឹក្សាជំនាញតាមវិស័យ | គ្មានទិន្នន័យគោល | ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលមានស្រាប់ទាំងបួន | ការអនុលោមតាមក្រុមប្រឹក្សាជំនាញតាមវិស័យផ្សេងទៀត និងនៅពេលដែលវាត្រូវបានបង្កើតឡើង | | ក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានការគាំទ្រពីអគ្គនាយកដ្ឋាន អ.ប.វ. ក្រសួង ក.ប. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០និង២០៥០ | |
| ១.១.៣ | បង្កើតកញ្ចប់ស្តង់ដាជំនាញសមត្ថភាព (កញ្ចប់កម្មវិធីសិក្សា សម្ភារសិក្សា និងកញ្ចប់វាយតម្លៃសមត្ថភាព) លើវិស័យអាទិភាពបន្ថែមទៀត | ចំនួនវិស័យ/ឧស្សាហកម្ម ដែលកញ្ចប់ត្រូវបានបង្កើតឡើង ឬកែសម្រួលឡើងវិញ | ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ២-៤ សម្រាប់វិស័យសំណង់ ការផលិតជាងម៉ាស៊ីន និងការងារអគ្គិសនី ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ៥ (ឌីប្លូម) សម្រាប់ការងារអគ្គិសនី | -វិស័យកាត់ដេរ និងវាយនភ័ណ្ឌ<br>-វិស័យរថយន្ត និងអេឡិចត្រូនិក<br>-វិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ | -វិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ<br>-វិស័យរថយន្ត និងអេឡិចត្រូនិក<br>-វិស័យកាត់ដេរ និងវាយនភ័ណ្ឌ<br>-វិស័យអាទិភាពផ្សេង | -ការជីករ៉ែ និងរុករករ៉ែ<br>-វិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ<br>-វិស័យអាទិភាពផ្សេង | ក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានការគាំទ្រពីក្រសួង ក.ប. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| ១.១.៤ | បង្កើតកម្មវិធីសិក្សានិងស្តង់ដាសមត្ថភាពសម្រាប់ការងារ / មុខរបរដែលទាក់ទងនឹងបដិវត្តឧស្សាហកម្ម ៤.០ ជំនាញនាពេលអនាគត និងសេដ្ឋកិច្ចបៃតង។ | ភាគរយនៃកម្មវិធីសិក្សានិងស្តង់ដាសមត្ថភាពត្រូវបានបង្កើតឡើងសម្រាប់កំណត់តួនាទីភារកិច្ចការងារ | គ្មានទិន្នន័យគោល | ៣០% | ៥០% | ៨០% | ក្រសួង ក.ប. ក្រសួង អ.យ.ក. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ គោលនយោបាយជាតិមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤, ៧ និង១៣ |
| ១.១.៥ | កំណត់ច្រកសិក្សាសម្រាប់ការចល័តទៅមក តាមកម្រិតផ្សេងៗ នៅក្នុងរចនាសម្ព័ន្ធប្រព័ន្ធ អ.ប.វ (ការអប់រំទូទៅ បច្ចេកទេស និងបច្ចេកវិទ្យា) | ឯកភាពគ្នាលើច្រក/ទិសដៅចល័តទៅមកនៅគ្រប់កម្រិតសិក្សា | ប្រព័ន្ធ អ.ប.វ. ដែលបានការឯក គ.ជ.ប.ប.នៅខែធ្នូ ឆ្នាំ ២០០០ កម្រិតទិសដៅចល័តមួយចំនួនដែលមានស្រាប់ | ១ | - | - | គ.ជ.ប.ប. អគ្គនាយកដ្ឋាន អ.ប.វ. ក្រសួង ក.ប. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅ នឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅ នឹងគោលដៅ អភិវឌ្ឍន៍ ប្រកបដោយ ចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេល មធ្យម ២០២៧-២០៣០ | រយៈពេល វែង ២០៣១-២០៣៥ | | | |
| ១.១.៦ | ការបន្សុីទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ទៅនឹងក្របខ័ណ្ឌបណ្តារប្រទេសក្នុងតំបន់ ឬអន្តរជាតិ (ដូចជាប្រទេស សិង្ហបុរី ឥណ្ឌា) | ចំនួនក្របខ័ណ្ឌនៅក្នុងតំបន់ / សកលលោក ដែលបន្សុីនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា | ក្នុងនាមជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាត្រូវបន្សុីទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិប្រចាំតំបន់ | ៥ | ១០ | ១៥ | គ.ជ.ប.ប.<br>អគ្គនាយកដ្ឋាន អ.ប.វ.<br>ក្រសួង ក.ប. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥<br>ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ | គោលដៅទី៤ |
| ១.១.៧ | អនុវត្តប្រព័ន្ធធានាគុណភាពដោយផ្អែកលើក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាសម្រាប់ទាំងគ្រឹះស្ថាន អ.ប.វ. សាធារណៈ និងឯកជននៅទូទាំងប្រទេស | គ្រឹះស្ថាន អ.ប.វ. ទាំងអស់ អនុវត្តតាម | គ្រឹះស្ថាន អ.ប.វ. ទាំងអស់ ដែលស្ថិតនៅក្រោមក្រសួង ក.ប. គឺស្ថិតនៅក្រោមការធ្វើសវនកម្មគុណភាព | គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្រោមក្រសួងផ្សេងៗ | គ្រឹះស្ថាន អ.ប.វ. ទាំងអស់ដែលមិនមែនជាគ្រឹះស្ថាន | - | ក្រសួង ក.ប.<br>ក្រសួង អ.យ.ក.គឺជាស្ថាប័នធានាដល់ការពិនិត្យនិងវាយតម្លៃ<br>អគ្គនាយកដ្ឋានអបវ. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥<br>ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣<br>ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅ នឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅ នឹងគោលដៅ អភិវឌ្ឍន៍ ប្រកបដោយ ចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេល មធ្យម ២០២៧-២០៣០ | រយៈពេល វែង ២០៣១-២០៣៥ | | | |
| ១.១.៨ | ការបន្សុីគ្នានៃកម្មវិធីដែលមាន ស្រាប់ដែលស្ថិតនៅក្រោម ក្រសួងផ្សេងៗ ឱ្យត្រូវនឹង ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា | ភាគរយនៃវគ្គ សិក្សា និងកម្រិត ឱ្យស្របទៅនឹង ក្របខ័ណ្ឌគុណ វុឌ្ឍិជាតិកម្ពុជា | កម្មវិធីទាំងអស់ ដែលស្ថិតនៅ ក្រោមក្រសួង ក.ប. គឺស្របទៅ នឹងក្របខ័ណ្ឌ គុណវុឌ្ឍិជាតិ កម្ពុជា | ១០០% នៃវិ ស័យអាទិ ភាពនៅ ក្រោម IDP ឆ្នាំ២០១៥-២០២៥ | ការបន្សុីនៃ វិស័យដទៃ ទៀតដែល បានកំណត់ សម្រាប់ រយៈពេល នេះ | ការបន្សុីនៃ វិស័យដទៃ ទៀតដែល បានកំណត់ សម្រាប់រយៈ ពេលនេះ | អគ្គនាយកដ្ឋាន អ.ប.វ.<br>ក្រសួង ក.ប. ក្រសួង អ.យ.ក និងក្រសួងពាក់ព័ន្ធ ផ្សេងៗទៀត | គោលនយោបាយ ជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាព យុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |
| ១.១.៩ | បង្កើតគោលការណ៍ណែនាំ/ លក្ខណវិនិច្ឆ័យសម្រាប់ទទួល ស្គាល់គុណភាពវគ្គសិក្សាដែល អង្គការមិនមែនរដ្ឋាភិបាល និង អ្នកផ្តល់ការបណ្តុះបណ្តាល ឯកជនរួមមាន(មិនកំណត់)៖<br>• វិសាលភាព<br>• ដំណើរការនៃការទទួល ស្គាល់វគ្គបណ្តុះបណ្តាល | ភាគរយនៃវគ្គ សិក្សាដែលបាន ទទួលស្គាល់ គុណភាព តាម គោលការណ៍ ដែលបានបង្កើត ឡើង | ការទទួលស្គាល់ គុណភាពវគ្គ សិក្សាដែលបាន អភិវឌ្ឍហើយ ជា ផ្នែកមួយនៃ គម្រោង TVETSDP របស់ ADB និង AFD ផ្នែកអគ្គិស- នីនិងការផលិត | ៣០% | ៥០% | ៨០% | គណៈកម្មការ ស្តង់ដាជាតិសមត្ថ ភាព និងធ្វើតេស្ត នៃគ.ជ.ប.ប. | គោលនយោបាយ ជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាព យុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅ នឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅ នឹងគោលដៅ អភិវឌ្ឍន៍ ប្រកបដោយ ចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេល មធ្យម ២០២៧-២០៣០ | រយៈពេល វែង ២០៣១-២០៣៥ | | | |
| | • វគ្គបណ្តុះបណ្តាលជំនាញ រដ្ឋបាល (រយៈពេល សម្ភារ បរិក្ខារ និងសមត្ថ ភាពគ្រូ។ល។) | | | | | | | | |
| **១.២.ការកែលម្អការកសាងសមត្ថភាពគ្រូបណ្តុះបណ្តាលរបស់ អ.ប.វ.** | | | | | | | | | |
| ១.២.១ | បង្កើតសៀវភៅណែនាំគោល នយោបាយធនធានមនុស្ស (HR) នៅទូទាំងប្រទេស សម្រាប់គ្រូឧទ្ទេស អ.ប.វ. ដែលគ្របដណ្តប់លើទិដ្ឋភាព (មិនកំណត់)៖<br>• បទដ្ឋាននៃការជ្រើសរើស បុគ្គលិក និងការដាក់ ឱ្យប្រើប្រាស់ (រួមទាំងគ្រូ ឧទ្ទេស ដែលមានបទ ពិសោធន៍ផ្នែកឧស្សាហកម្ម វិទ្យាស្ថានបណ្តុះ | ការអនុលោម តាមសៀវភៅ ណែនាំគោល នយោបាយ ធនធាន មនុស្ស ដោយ វិទ្យាស្ថាន អ.ប.វ. | គ្មានទិន្នន័យ គោល | គ្រឹះស្ថាន អ.ប.វ. ទាំង អស់ | គ្រប់គ្រឹះ ស្ថាន អ.ប.វ. សាធារណៈ ទាំងអស់ (លើក លែងតែ វិទ្យាស្ថាន បណ្តុះ បណ្តាល ជំនាញ) | គ្រឹះស្ថាន អ.ប.វ. ទាំង អស់ ដែល មិនមែនជា សាធារណៈ | អគ្គនាយកដ្ឋាន អ.ប.វ. ក្រសួង ក.ប. ដោយមានការគាំ ទ្រពី ក្រសួង អ.យ.ក. និងក្រុមប្រឹក្សា ជំនាញតាមវិស័យ | គោលនយោបាយ ជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាព យុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅ អភិវឌ្ឍន៍ ប្រកបដោយ ចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេល មធ្យម ២០២៧-២០៣០ | រយៈពេល វែង ២០៣១-២០៣៥ | | | |
| | បណ្តាលជំនាញ សាធារណៈ)៖<br>• ប្រភពនៃការជ្រើសរើស បុគ្គលិក<br>• ប្រភេទការងារ និងលក្ខណៈ នៃការងារ<br>• ការវាយតម្លៃ និងការ ជ្រើសរើស<br>• បែបបទនៃការតែងតាំង<br>• អត្ថប្រយោជន៍ផ្សេងៗ<br>• ការសាកល្បង និងការ បញ្ជាក់<br>• ផែនការសំណង | | | | | | | | |
| ១.២.២ | បង្កើតក្របខ័ណ្ឌរួមមួយ សម្រាប់ការទទួលស្គាល់ គ្រូ | ការអនុលោម តាមក្របខ័ណ្ឌ | គ្មានទិន្នន័យ គោល | វិទ្យាស្ថាន ជាតិបណ្តុះ | គ្រប់គ្រឹះស្ថាន/ ក្រុមប្រឹក្សា ជំនាញតាម | | អគ្គនាយកដ្ឋាន អ.ប.វ. ក្រសួង ក.ប. ដោយមានការគាំ | គោលនយោបាយ ជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ | |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅ នឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅ នឹងគោលដៅ អភិវឌ្ឍន៍ ប្រកបដោយ ចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេល មធ្យម ២០២៧-២០៣០ | រយៈពេល វែង ២០៣១-២០៣៥ | | | |
| | ឧទ្ទេសឱ្យស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា | ដែលបានបង្កើតឡើង | | បណ្ដាលបច្ចេកទេស | វិស័យដែលអនុវត្តការបណ្តុះបណ្តាលគ្រូឧទ្ទេស | | ទ្រពីក្រសួង អ.យ.ក. និងក្រុមប្រឹក្សាជំនាញតាមវិស័យ | ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង២០៥០ | |
| ១.២.៣ | បង្កើតគោលការណ៍ណែនាំទូទៅសម្រាប់ការបណ្តុះបណ្តាលគ្រូបង្គោលរួមមាន៖<br>• លក្ខខណ្ឌតម្រូវការចូល បំរើការងារ<br>• រចនាសម្ព័ន្ធស្តង់ដានៃ ការបណ្តុះបណ្តាលគ្រូឧទ្ទេស<br>• មាតិកាស្តង់ដា<br>• លក្ខណវិនិច្ឆ័យក្នុងការវាយតម្លៃ | ការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ណែនាំដែលបានបង្កើតឡើង | គ្មានទិន្នន័យគោល | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | គ្រប់វិទ្យាស្ថាន/ក្រុមប្រឹក្សាជំនាញតាមវិស័យ ដែលអនុវត្តការបណ្តុះបណ្តាលគ្រូឧទ្ទេស | | អគ្គនាយកដ្ឋាន អ.ប.វ. ក្រសួង ក.ប. ដោយមានការគាំទ្រពីក្រសួង អ.យ.ក. និងក្រុមប្រឹក្សាជំនាញតាមវិស័យ | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង២០៥០ | |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | • កម្រិត និងការផ្តល់គុណវុឌ្ឍិដល់គ្រូឧទ្ទេស | | | | | | | | |
| ១.២.៤ | ពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងសមត្ថភាពរបស់ វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសទាក់ទងនឹងការបង្រៀនគរុកោសល្យ និងបច្ចេកទេសថ្មីៗ | ភាគរយនៃបុគ្គលិកវិទ្យាស្ថានជាតិ បណ្តុះបណ្តាលបច្ចេកទេស ដែលមានសមត្ថភាព | គ្រូឧទ្ទេសចំនួន ២០ នាក់របស់វិទ្យាស្ថានជាតិ បណ្តុះបណ្តាលបច្ចេកទេសបានបណ្តុះបណ្តាលសាកល្បង (ឆ្នាំ២០១៦) គ្រូរបស់ អ.ប.វ. ចំនួន ៣០០ នាក់ នឹងបញ្ចប់ការសិក្សាពីវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសជារៀងរាល់ឆ្នាំចាប់ | ៣០% | ៥០% | ៨០% | ក្រសួង ក.ប. ដោយមានការគាំទ្រពីក្រសួង អ.យ.ក. និងក្រសួងផ្សេងៗទៀត | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | ផ្តើមនៅក្នុងឆ្នាំ ២០១១ | | | | | | |
| ១.២.៥ | កសាងសមត្ថភាពរបស់គ្រឹះស្ថាន អ.ប.វ. និង ក្រុមប្រឹក្សាជំនាញតាមវិស័យ ដើម្បីអនុវត្តការបណ្តុះបណ្តាលគ្រូឧទ្ទេស | ភាគរយនៃគ្រឹះស្ថាន អ.ប.វ. និង ក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានសមត្ថភាព | គ្មានទិន្នន័យគោល | គ្រឹះស្ថាន អ.ប.វ.៖ ១០% ក្រុមប្រឹក្សាជំនាញតាមវិស័យ៖ ចំនួន៤ ដែលមានស្រាប់ | គ្រឹះស្ថានអ.ប.វ.៖ ២០% ក្រុមប្រឹក្សាជំនាញតាមវិស័យ៖ ក្រុមប្រឹក្សាជំនាញតាមវិស័យទើបបង្កើតថ្មី | គ្រឹះស្ថាន អ.ប.វ.៖ ៣០% ក្រុមប្រឹក្សាជំនាញតាមវិស័យ៖ ក្រុមប្រឹក្សាជំនាញតាមវិស័យទើបបង្កើតថ្មី | ក្រសួង ក.ប. ដោយមានការគាំទ្រពីក្រសួង អ.យ.ក. និងក្រសួងផ្សេងៗទៀត | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |
| ១.២.៦ | ការពង្រីកកម្មវិធីត្រឡប់ទៅឧស្សាហកម្មវិញ (RIS) សម្រាប់គ្រូដែលមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស | ចំនួននៃគ្រូបណ្តុះបណ្តាលដែលជាផ្នែកមួយនៃ RIS | គ្រូបណ្តុះបណ្តាល CBT ចំនួន ២៥៦ បានបញ្ចប់ RIS សម្រាប់វិស័យ | ៣០០ | ៤០០ | ៥០០ | ក្រសួង ក.ប. ដោយមានការគាំទ្រពី ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | អាទិភាពដែលបានអនុវត្តក្រោមគម្រោង TVETSDP | | | | និងក្រសួងផ្សេងៗទៀត | ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | |
| ១.៣.ការបង្កើតកញ្ចប់បណ្តុះបណ្តាលម៉ូឌុល ម៉ូឌុលសិក្សាតាមអនឡាញ និងការរួមបញ្ចូលជំនាញទន់នៅក្នុងកម្មវិធី អ.ប.វ. ទាំងអស់ | | | | | | | | | |
| ១.៣.១ | បង្កើតម៉ូឌុលសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដោយផ្អែកលើកម្មវិធី អ.ប.វ. ដែលមានស្រាប់ | ភាគរយនៃវគ្គសិក្សាតាមឌីជីថលដែលបានបង្កើតឡើង | UNIDO បានបង្កើតម៉ូឌុលឌីជីថលសម្រាប់វិស័យ T&A | ៣០% | ៥០% | ១០០% | ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ ក្របខ័ណ្ឌគោលនយោបាយសង្គម និងសេដ្ឋកិច្ចឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | | | | | | | |
| ១.៣.២ | ជំរុញឱ្យមានភាពបត់បែនសម្រាប់វគ្គបណ្ដុះបណ្ដាលផ្អែកលើម៉ូឌុល លើវគ្គវិញ្ញាបនបត្រ Micro/Nano | ចំនួនវគ្គបណ្ដុះបណ្ដាលផ្អែកលើម៉ូឌុលដែលត្រូវបានបង្កើតឡើងជាច្រើនសម្រាប់វិស័យ/ឧស្សាហកម្ម | ក្រោមគម្រោង TVETSDP ផ្អែកលើម៉ូឌុល និងសម្ភារសិក្សា និងការវាយតម្លៃកំពុងត្រូវបានបង្កើតឡើងសម្រាប់មុខរបរការថែទាំនិងជួសជុលអគ្គិសនីរថយន្ត (ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត ២) ការងារកំបោរ (ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា | សម្លៀកបំពាក់ និងវាយនភ័ណ្ឌ<br>វិស័យទេសចរណ៍បដិសណ្ឋារកិច្ច និងការធ្វើដំណើរ | វិស័យទេសចរណ៍បដិសណ្ឋារកិច្ច និងការធ្វើដំណើរ | វិស័យទេសចរណ៍បដិសណ្ឋារកិច្ច និងការធ្វើដំណើរ<br>ការជីករ៉ែ និងការរុករករ៉ែ | ក្រសួង ក.ប.<br>ក្រសួង អ.យ.ក.<br>ក្រសួងទេសចរណ៍<br>ក្រសួង ស.ហ.វ. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្រ្ត | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | កម្រិត២) សេវាកម្មកុំព្យូទ័រ (ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត២) | | | | | | |
| ១.៣.៣ | ការកំណត់ និងការអនុម័តបច្ចេកវិទ្យាថ្មីក្នុងគោលបំណងផ្តល់ការបណ្តុះបណ្តាលដោយមជ្ឈមណ្ឌលឧត្តមភាពតាមរយៈការបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាកម្រិតខ្ពស់ (CAT)[1] | ចំនួនមជ្ឈមណ្ឌលបច្ចេកវិទ្យាកម្រិតខ្ពស់ដែលបានបង្កើតឡើង (តាមតំបន់) | គ្មានទិន្នន័យគោល | ១ | ១ | ១ | ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ ក្របខ័ណ្ឌគោលនយោបាយសង្គម និងសេដ្ឋកិច្ចឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |

[1] វានឹងបម្រើជាមជ្ឈមណ្ឌលជំនាញមួយដែលនិស្សិតមកពីវគ្គសិក្សា/កម្មវិធីផ្សេងៗ នឹងប្រើការសិក្សាជាក់ស្តែងបែបនិម្មិត ៣D AI និងបច្ចេកវិទ្យាកម្រិតខ្ពស់ផ្សេងទៀតដើម្បី "ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ" ដំណើរការការងារ និងបរិស្ថាន។

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| ១.៣.៤ | ការអភិវឌ្ឍកម្មវិធី /ម៉ូឌុលសិក្សាលើជំនាញទន់ និងសម្ភារបណ្តុះបណ្តាល (រួមទាំងគោលការណ៍ណែនាំគ្រូឧទ្ទេស គោលការណ៍ណែនាំលើការវាយតម្លៃសមត្ថភាព) បន្ទាប់ពីស្តង់ដាសមត្ថភាពត្រូវបានផ្តល់សុពលភាពដោយឧស្សាហកម្ម | កម្មវិធី/ម៉ូឌុលសិក្សាត្រូវបានអភិវឌ្ឍសម្ភារបណ្តុះបណ្តាល | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស បានអភិវឌ្ឍម៉ូឌុលចំនួន ៦ លើជំនាញទន់ | ៨ | ១០ | ១២ | ការិយាល័យអភិវឌ្ឍន៍ជំនាញទន់នៃនាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សាដោយមានការគាំទ្រពីក្រុមប្រឹក្សាជំនាញតាមវិស័យ CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ គោលនយោបាយជាតិមុខរបរ និងការងារ ឆ្នាំ ២០១៥-២០២៥ IDP ២០១៥-២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |
| ១.៣.៥ | បញ្ចូលជំនាញទន់ទៅក្នុងកម្មវិធីសិក្សាសម្រាប់ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ៥ ឡើងទៅ | ភាគរយនៃជំនាញទន់ ដែលបានដាក់បញ្ចូលកម្មវិធី អ.ប.វ. | ម៉ូឌុលបណ្តុះបណ្តាលជំនាញទន់ត្រូវបានអភិវឌ្ឍ និងដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសម្រាប់ក្របខ័ណ្ឌគុណវុឌ្ឍិ | ៣០% | ៣០% | ៤០% | អគ្គនាយកដ្ឋាន អ.ប.វ.ដោយមានការគាំទ្រពីក្រុមប្រឹក្សាជំនាញតាមវិស័យ | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ គោលនយោបាយជាតិមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | ជាតិកម្ពុជា កម្រិត ១-៤ | | | | | IDP ២០១៥-២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | |
| **១.៤. ការធ្វើបរិវត្តកម្មគ្រឹះស្ថាន អ.ប.វ. មួយចំនួន ជាគ្រឹះស្ថាន អ.ប.វ. ឈានមុខ ឬជាគ្រឹះស្ថាន អ.ប.វ. ភូមិភាគ** | | | | | | | | | |
| ១.៤.១ | កែទម្រង់គ្រឹះស្ថាន អ.ប.វ (តាមរយៈការធ្វើឱ្យប្រសើរឡើងនូវរូបវន្តបណ្តុះបណ្តាល - ការយកចិត្តទុកដាក់លើយេនឌ័រ និងការរៀបចំការសន្សំសំចៃថាមពល) ឱ្យក្លាយជាគ្រឹះស្ថាន អ.ប.វ. ឈានមុខគេក្នុងការកែលម្អគុណភាព និងភាពពាក់ព័ន្ធនៃឧស្សាហកម្មរបស់ប្រព័ន្ធ អ.ប.វ. | ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលជំនាញដែលបានផ្លាស់ប្តូរ | ៤ គ្រឹះស្ថានអ.ប.វ. ដែលស្ថិតក្រោមអគ្គនាយកដ្ឋាន អ.ប.វ/ក្រសួង ក.ប. និង ITC របស់ក្រសួង អ.យ.ក. កំពុងធ្វើឱ្យប្រសើរឡើង / បរិវត្តកម្មក្រោមគម្រោង គម្រោងជំនាញសម្រាប់ការ | ៥ | ៣ | ៤ | ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេល មធ្យម ២០២៧-២០៣០ | រយៈពេល វែង ២០៣១-២០៣៥ | | | |
| | | | ប្រកួតប្រជែង (S4C) | | | | | | |
| ១.៤.២ | ប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលជំនាញឱ្យក្លាយជាស្ថាប័នរដ្ឋបាលសាធារណៈ ដើម្បីដើរតួជាគ្រឹះស្ថាន អ.ប.វ ភូមិភាគសម្រាប់៖<br>• ការបង្កើនជំនាញគ្រូបច្ចេកទេស<br>• ការអភិវឌ្ឍវគ្គសិក្សា អ.ប.វ. តាមប្រព័ន្ធអនឡាញ<br>• ការត្រួតពិនិត្យទីផ្សារការងារ | ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលជំនាញ ដែលបានកែទម្រង់ | មានគ្រឹះស្ថានបណ្តុះបណ្តាលជំនាញចំនួន៥ ក្នុងទម្រង់ជាគ្រឹះស្ថានភូមិភាគតាមតំបន់ (RTC) | ៣ | ២ | ២ | ក្រសួង ក.ប. ក្រសួង អ.យ.ក. និងក្រសួង ស.ហ.វ . | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ២០១៧-២០២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |
| **១.៥. ការផ្តល់ការបណ្តុះបណ្តាលជំនាញសម្រាប់តម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត ដោយរួមបញ្ចូលជំនាញសម្រាប់បដិវត្តន៍ឧស្សាហកម្មទី ៤ និងសេដ្ឋកិច្ចបៃតង** | | | | | | | | | |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| ១.៥.១ | ការវិភាគព្យាករណ៍ទីផ្សារការងារ និងការវាយតម្លៃតម្រូវការជំនាញ (ការសិក្សាអំពីគម្លាតជំនាញថ្នាក់ជាតិ ថ្នាក់ខេត្ត និងវិស័យ) រួមទាំងការងារ / មុខរបរទាក់ទងនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ សេដ្ឋកិច្ចបៃតង | ការសិក្សាមួយចំនួនដែលបានធ្វើឡើងនៅគ្រប់កម្រិតដែលបានបញ្ជាក់ | ទីភ្នាក់ងារជាតិការងារបានធ្វើការសិក្សាប្រចាំឆ្នាំអំពីគម្លាតជំនាញនៅថ្នាក់ជាតិ | ការសិក្សា ១ ដងប្រចាំឆ្នាំ | ការសិក្សា ១ ដងប្រចាំឆ្នាំ | ការសិក្សា ១ ដងប្រចាំឆ្នាំ | ទ.ជ.ម.ក អគ្គនាយកដ្ឋាន អ.ប.វ. វិទ្យាស្ថានជាតិស្ថិតិ CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៤.៤.៣) គោលនយោបាយជាតិមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ IDP ២០១៥-២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |
| ១.៥.២ | ធ្វើការសិក្សាតាមដានវាយតម្លៃសិស្សដែលបានបញ្ចប់ការសិក្សានៅ អ.ប.វ.ជាប្រចាំ | ចំនួននៃការសិក្សាតាមដានត្រូវបានធ្វើឡើង | ការសិក្សាតាមដានត្រូវបានធ្វើឡើងសម្រាប់សិស្សបញ្ចប់ការសិក្សានៃគម្រោងកម្មវិធីអភិវឌ្ឍជំនាញរបស់ SDC (៦ និង | ការសិក្សា ១ ដងប្រចាំឆ្នាំ | ការសិក្សា ១ ដង ប្រចាំឆ្នាំ | ការសិក្សា ១ ដងប្រចាំឆ្នាំ | ទ.ជ.ម.ក អគ្គនាយកដ្ឋាន អ.ប.វ. វិទ្យាស្ថានជាតិស្ថិតិ CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៤.៤.៣) គោលនយោបាយជាតិមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | ១២ ខែបន្ទាប់ពីការបញ្ចប់វគ្គសិក្សានីមួយៗ) | | | | | IDP ២០១៥-២៥ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | |
| **១.៦.ការពង្រឹងក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានស្រាប់** | | | | | | | | | |
| ១.៦.១ | ពង្រឹងក្រុមប្រឹក្សាជំនាញតាមវិស័យដែលមានស្រាប់៖<br>• បង្កើតក្រុមអ្នកបណ្តុះបណ្តាល និងអ្នកវាយតម្លៃខាងក្នុង<br>• ចូលរួមយ៉ាងសកម្មជាមួយប្រទេសមួយចំនួនសម្រាប់ការផ្ទេរបច្ចេកវិទ្យាក្នុងការបណ្តុះបណ្តាលជំនាញ ការបណ្តុះបណ្តាលគ្រូបង្គោល ការបង្កើត | ចំនួនក្រុមប្រឹក្សាជំនាញតាមវិស័យដែលត្រូវបានពង្រឹង | គ្មានទិន្នន័យគោល | ៤ | ៥ | ៨ | ក្រសួង ក.ប. ក្រសួង អ.យ.ក. CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៣.១.៤) ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០និង២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | មជ្ឈមណ្ឌលគំរូ និងឧត្តមភាព<br>• ធ្វើការសិក្សាតាមវិស័យ និងដើរតួជាច្រកចេញចូលតែមួយក្នុងការផ្សព្វផ្សាយចំណេះដឹងឧស្សាហកម្មដែលកំពុងត្រូវបានបង្កើត ឬអភិវឌ្ឍពាសពេញពិភពលោកសម្រាប់អ្នកពាក់ព័ន្ធ<br>• បង្កើតច្រកផ្សព្វផ្សាយការងារ និងកម្មវិធីចល័ត (Mobile app) | | | | | | | | |
| **១.៧. ការរៀបចំអភិក្រមសម្រាប់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈថ្មី ដែលរួមបញ្ចូលការអប់រំ និងជំនាញ** | | | | | | | | | |
| ១.៧.១ | កំណែទម្រង់ប្រព័ន្ធអប់រំមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិទៅជាប្រព័ន្ធ | គោលនយោបាយអប់រំថ្មីដែលមានអភិ | គ្មានទិន្នន័យគោល | - | ការបញ្ចប់គោលនយោបាយ | - | អគ្គនាយកដ្ឋាន អ.ប.វ ដោយមានការគាំទ្រពីក្រសួង | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | ពហុជំនាញ និងមានភាពទន់ភ្លន់ដែលមានច្រកចេញចូលច្រើន ដោយរួមបញ្ចូលការអប់រំអាជីព និងការអប់រំវិជ្ជាជីវៈ | ក្រមចម្រុះត្រូវបានបង្កើត និងអនុម័ត | | | អប់រំថ្មីដែលមានអភិក្រមចម្រុះ | | ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រុមប្រឹក្សាជំនាញតាមវិស័យ | ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | |
| **២.ការពង្រឹងកិត្តិនាម និងការផ្សព្វផ្សាយ** | | | | | | | | | |
| **២.១.ការបង្កើនការចូលរួម និងការយល់ដឹងអំពីការបណ្តុះបណ្តាលជំនាញ** | | | | | | | | | |
| ២.១.១ | អភិវឌ្ឍសម្ភារអប់រំផ្សព្វផ្សាយនៅទូទាំងប្រទេសដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព ការអភិវឌ្ឍជំនាញ ការទទួលស្គាល់***ការសិក្សាដែលមានពីមុន*** ការទទួល | ចំនួនក្រសួង និងគ្រឹះស្ថាន អ.ប.វ ដែលប្រើប្រាស់សម្ភារអប់រំបណ្តុះបណ្តាលត្រូវបានអភិវឌ្ឍ | ជាផ្នែកមួយនៃជំនាញរបស់ ADB សម្រាប់សម្ភារ IEC នៃគម្រោងប្រកួតប្រជែងដែល ត្រូវបានបង្កើតរួចហើយ | ក្រសួងទាំងអស់ គ្រឹះស្ថាន អ.ប.វ សាធារណៈទាំងអស់ | គ្រប់គ្រឹះស្ថានអ.ប.វ. ដែលមិនមែនរដ្ឋាភិបាលទាំងអស់ | - | គ.ជ.ប.ប. ក្រសួង ក.ប. ក្រសួង អ.យ.ក. CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៤.២.៤) ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | ស្គាល់សមត្ថភាពបច្ចុប្បន្នជាដើម | | | | | | | | |
| ២.១.២ | ផ្តោតទៅលើការផ្សព្វផ្សាយតាមរយៈទូតសុច្ឆន្ទៈជំនាញ រួមមានទាំងតួអង្គលេចធ្លោជាដើម | កម្មវិធីដែលបានរៀបចំមួយចំនួនតាមរយៈទូតសុច្ឆន្ទៈជំនាញ | គ្មានទិន្នន័យគោល | ១០ | ២០ | ៣០ | គ.ជ.ប.ប. ក្រសួង ក.ប. ក្រសួង អ.យ.ក. CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៤.២.៤) ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |
| **២.២.ការផ្តោតលើការកសាងកិត្តិនាម ការប្រឹក្សាយោបល់ និងការធ្វើការផ្សព្វផ្សាយជំនាញ (Skill Advocacy)** | | | | | | | | | |
| ២.២.១ | បង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយជំនាញ (Skill Advocacy) ធ្វើឱ្យ «ការអភិវឌ្ឍជំនាញនៅកម្ពុជា» មានកេរ្តិ៍ឈ្មោះក្នុងពិភពលោក និងអត្តសញ្ញាណសម្រាប់ប្រទេស។ យុទ្ធសាស្ត្រអាចរួមមានចំណុច ៖ | ការយកលំនាំតាម និងអនុវត្តយុទ្ធសាស្ត្រចុងក្រោយដោយក្រសួងគន្លឹះ និងគ្រឹះស្ថាន អ.ប.វ. ទាំងអស់ | ដោយជាផ្នែកមួយនៃជំនាញរបស់ ADB សម្រាប់គម្រោងប្រកួតប្រជែងមានអ្នកជំនាញទីផ្សារ អ.ប.វ. ដែលទទួលខុស | ក្រសួង ក.ប. ក្រសួង អ.យ.ក. គ្រប់គ្រឹះស្ថានសាធារណៈទាំង | ក្រសួងផ្សេងៗទៀត និងគ្រឹះស្ថាន អ.ប.វ. មិនមែនសាធារណៈ | - | គ.ជ.ប.ប. ក្រសួង ក.ប. ក្រសួង អ.យ.ក. CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៤.២.៤) ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | • រៀបចំយុទ្ធនាការទូទាំងប្រទេសដែលមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ<br>• ចូលរួមសន្និសិទថ្នាក់ជាតិ និងអន្តរជាតិ កិច្ចប្រជុំ និងសិក្ខាសាលា ការចូលរួមក្នុងការប្រឡងប្រណាំងជំនាញពិភពលោក<br>• អបអរសាទរទិវាជំនាញយុវជនពិភពលោក<br>• រៀបចំការធ្វើទស្សនកិច្ចសិក្សា | | ត្រូវក្នុងការរៀបចំផែនការទីផ្សារផលិតផលយុទ្ធសាស្ត្រ និងការធ្វើទីផ្សារសង្គម និងយុទ្ធនាការលើកកម្ពស់ការយល់ដឹង | អស់នៅក្រោម ក.ប. | | | | | |
| ២.២.២ | ការប្រឹក្សាយោបល់ និងការណែនាំដើម្បីលើកទឹកចិត្ត និងបង្កើតសេចក្តីប្រាថ្នាដល់ក្រុមដែលបាត់បង់ឱកាស | ចំនួនវគ្គប្រឹក្សាយោបល់ដែលបានរៀបចំ | ការប្រឹក្សាយោបល់ជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍ជំនាញរបស់ SDC | ១០ | ២០ | ៣០ | ក្រសួង ក.ន.<br>ក្រសួង ស.អ.យ.<br>ក្រសួង ក.ប.<br>ក្រសួង អ.យ.ក.<br>CAMFEBA | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៤.២.៤) ចក្ខុវិស័យកម្ពុជា | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | | | | | | ឆ្នាំ២០៣០និង ២០៥០ | |
| ២.៣.ការកែលម្អប្រកបង្កើនលទ្ធភាពចូលសិក្សា ដល់ក្រុមដែលបាត់បង់ឱកាស | | | | | | | | | |
| ២.៣.១ | អភិវឌ្ឍភាគរយនៃគោលការណ៍ណែនាំសម្រាប់អ្នកផ្តល់សេវាការបណ្តុះបណ្តាលទាំងអស់ដើម្បីធានាបាននូវបរិយាកាសបណ្តុះបណ្តាលប្រកបដោយបរិយាបន្ន យេនឌ័រ និងសង្គម | ចំនួននៃ TPs ដែលអនុលោមតាមបរិយាកាសបណ្តុះបណ្តាលចាំបាច់ | សៀវភៅណែនាំអំពីការអនុវត្តសម្រាប់បរិយាបន្នសង្គម និងសុខុមាលភាពដែលត្រូវបានបង្កើតឡើងដោយ SDC នៅក្នុងឆ្នាំ២០២០ អាចត្រូវបានបង្កើនប្រសិទ្ធភាព | ១០០% | ១០០% | ១០០% | ក្រសួង ក.ន.<br>ក្រសួង ស.អ.យ.<br>ក្រសួង ក.ប.<br>ក្រសួងទេសចរណ៍<br>ក្រសួង អ.យ.ក. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៤.២.៤)<br>ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០/២០៥០ (៣.១.២) ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ | គោលដៅទី៤, ៥ និង៨ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| ២.៣.២ | ជ្រើសរើសមុខរបរផ្អែកលើតម្រូវការ | ចំនួនមុខរបរថ្មីដែលត្រូវបានកំណត់សម្រាប់ការបណ្តុះបណ្តាលជនមកពីក្រុមជនងាយរងគ្រោះ | ១២ (ជាងម៉ូតូ ជាងម៉ាស៊ីនតូច អ្នកតុបតែង ជាងកាត់ដេរ ជាងរៀបតង្ហ ជាងភ្លើង ជាងទឹក ជាងផ្សារដែក ជំនួយការចុងភៅ ជំនួយការកែច្នៃចំណីអាហារ ជាងម៉ាស៊ីនត្រជាក់ ជាងកាត់សក់) ត្រូវបានកំណត់ថាជាផ្នែកមួយនៃគម្រោងជំនាញអភិវឌ្ឍន៍របស់ SDC | ១០ | ២០ | ៣០ | ក្រសួង ក.ន.<br>ក្រសួង ស.អ.យ.<br>ក្រសួង ក.ប.<br>ក្រសួង អ.យ.ក. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៣.១.២)<br>ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤, ៥ និង៨ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| ២.៣.៣ | បង្កើតមជ្ឈមណ្ឌលសេវាប្រឹក្សាយោបល់នៅតាមថ្នាក់ខេត្ត និងសហគមន៍ដោយសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកសម្រាប់ស្ត្រី និងក្រុមងាយរងគ្រោះ | ចំនួនមជ្ឈមណ្ឌលសេវាប្រឹក្សាយោបល់ដែលត្រូវបានបង្កើតឡើង | គ្មានទិន្នន័យគោល | ១ នៅតាមខេត្ត និងសហគមន៍នីមួយៗលើមូលដ្ឋាននៃការសាកល្បង | បន្តបង្កើតនៅតាមខេត្ត និងសហគមន៍ផ្សេងទៀត | | ក្រសួង ក.ន. ក្រសួង ស.អ.យ. ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ស.ហ.វ. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ (៣.១.២) ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤, ៥ និង៨ |
| ២.៣.៤ | ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលការងារប្រចាំតំបន់ ដើម្បីជួយដល់អ្នកស្វែងរកការងារ និងសិស្ស-និស្សិត | ចំនួនមជ្ឈមណ្ឌលការងារដែលត្រូវបានពង្រឹង | មជ្ឈមណ្ឌលការងារចំនួន ១៣ ដែលមានស្រាប់ | ៤ | ៤ | ៥ | ទ.ជ.ម.ក. គាំទ្រពី ក្រសួង ក.ប. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជា | គោលដៅទី៤, ៥ និង ៨ |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| | | | | | | | | ឆ្នាំ២០៣០និង ២០៥០ | |
| **២.៤.ការលើកកម្ពស់សហគ្រិនភាព** | | | | | | | | | |
| ២.៤.១ | បង្កើតគោលការណ៍ណែនាំសហគ្រិនភាពដែលទាក់ទងទៅនឹងការផ្តល់ហិរញ្ញប្បទានសម្រាប់សិស្សបញ្ចប់ការសិក្សានៅ អ.ប.វ. និងការអភិវឌ្ឍន៍ស្តង់ដារសមត្ថភាព និងកម្មវិធីសិក្សា | ការអនុលោមតាមគោលការណ៍ណែនាំដែលបង្កើតឡើងដោយគ្រឹះស្ថាន អ.ប.វ. និងក្រុមប្រឹក្សាជំនាញតាមវិស័យ | ប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណើរការនៃការបង្កើតគោលការណ៍ណែនាំដោយមានការគាំទ្រពី ILO | ៤០% | ៦០% | ១០០% | ក្រសួង ក.ប. ក្រសួង អ.យ.ក. ក្រសួង ឧ.វ.ប.ន. | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍កម្ពុជាឆ្នាំ ២០៣០ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |

| ល.រ | សសរស្តម្ភ គោលដៅអន្តរាគមន៍ | សូចនាករសមិទ្ធកម្ម | សូចនាករឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័នទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| ២.៥.ការផ្តល់ឱកាសការហ្វឹកហ្វឺនកូនជាង(Apprenticeship) សម្រាប់ការងារ | | | | | | | | | |
| ២.៥.១ | ធ្វើវិសោធនកម្មគោលការណ៍ណែនាំស្តីពីការហ្វឹកហ្វឺនកូនជាងដើម្បីពង្រីកការគ្របដណ្តប់ការហ្វឹកហ្វឺនកូនជាង | ភាគរយនៃឧស្សាហកម្មដែលអនុលោមតាមគោលការណ៍ណែនាំដែលបានធ្វើវិសោធនកម្មថ្មី | គ្មានទិន្នន័យគោល | ១០០% | ១០០% | ១០០% | អគ្គនាយកដ្ឋាន អ.ប.វ.<br>ក្រសួង ក.ប.<br>ក្រសួង អ.យ.ក.<br>ក្រុមប្រឹក្សាជំនាញតាមវិស័យ | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥<br>គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ ២០១៥-២០២៥<br>IDP ឆ្នាំ២០១៥-២៥<br>ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ និង៨ |
| ៣.អ.ប.វ. ដែលឆ្លើយតបនឹងឧស្សាហកម្ម | | | | | | | | | |
| ៣.១.ការលើកកម្ពស់តួនាទី និងការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍជំនាញ | | | | | | | | | |

| ល.រ | សសរស្តម្ភ គោលដៅ អន្តរាគមន៍ | សូចនាករ សមិទ្ធកម្ម | សូចនាករ ឆ្នាំមូលដ្ឋាន (២០២១) | សូចនាករគោលដៅ | | | ក្រសួង/ ស្ថាប័ន ទទួលខុសត្រូវ | ភាពស្របគ្នាទៅនឹងយុទ្ធសាស្ត្រ | ភាពស្របគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
|---|---|---|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី ២០២៣-២០២៦ | រយៈពេលមធ្យម ២០២៧-២០៣០ | រយៈពេលវែង ២០៣១-២០៣៥ | | | |
| ៣.១.១ | ការអភិវឌ្ឍន៍ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ភាពជាដៃគូក្នុងស្ថាប័នជាមួយនឹងឧស្សាហកម្មសម្រាប់ទិដ្ឋភាពផ្សេងៗ | អភិវឌ្ឍក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការអនុវត្តបញ្ជីដៃគូដែលមានសក្តានុពល | គ្មានទិន្នន័យគោល | យុទ្ធសាស្ត្រត្រូវបានបង្កើតឡើង | - | - | ក្រសួង ក.ប. ក្រសួង អ.យ.ក. ដោយមានការគាំទ្រពីក្រសួងផ្សេងៗទៀត | គោលនយោបាយជាតិ អ.ប.វ. ឆ្នាំ ២០១៧-២០២៥ ផែនការសកម្មភាពយុទ្ធសាស្ត្រ អ.ប.វ. ឆ្នាំ២០១៩-២០២៣ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង ២០៥០ | គោលដៅទី៤ |
